ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសុខាភិបាល

# សេចក្តីណែនាំផ្នែកបច្ចេកទេសសម្រាប់ការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ


រៀបរៀងដោយៈ
- នាយកដ្ឋានមន្ទីរពេទ្យ
- ក្រុមរោងជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ
- JICA MEDEM2 Project


ខែធ្នូ ឆ្នាំ២០១១


ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

# អារម្ភកថា

ឧបករណ៍បរិក្ខារពេទ្យជាវត្ថុដ៏មានសារៈប្រយោជន៍ក្នុងការស្រាវជ្រាវរករោគវិនិច្ឆ័យ និងព្យាបាលជំងឺ ។ ដូចនេះ ការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងថែទាំឧបករណ៍បរិក្ខារពេទ្យ គឺជាកិរិយាបថសំខាន់ចូលរួមក្នុងការផ្តល់សេវាសុខភាពប្រកបដោយគុណភាព ប្រសិទ្ធភាព សុវត្ថិភាព និងប្រសិទ្ធផល ស្របទៅនឹងទិសដៅគោលនយោបាយរបស់ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ ដែលបានកំណត់ទិសដៅអាទិភាពមួយគឺ បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តឧបករណ៍បរិក្ខារពេទ្យ និងបច្ចេកវិទ្យាទំនើបជាមួយនឹងការលើកកំពស់សេវាគាំទ្រមិនមែនវេជ្ជសាស្ត្រ ការគ្រប់គ្រងថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ និងប្រព័ន្ធផ្គត់ផ្គង់ឱសថឧបករណ៍បរិក្ខារពេទ្យ ។

ចាប់ពីឆ្នាំ ២០០៦ មកដល់បច្ចុប្បន្នក្រសួងសុខាភិបាលសហការជាមួយអង្គការ JICA បាននិងកំពុងបន្តអនុវត្តគម្រោងពង្រឹងប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅតាមមន្ទីរពេទ្យជាតិមួយចំនួន មន្ទីរពេទ្យបង្អែកកម្រិត CPA3 និងពង្រីកដល់មន្ទីរពេទ្យកម្រិត CPA2 ជាបន្តទៅទៀត (MEDEM-1 Project និង MEDEM-2 Project) ។ ឆ្លងកាត់បទពិសោធន៍ទទួលបានក្នុងការអនុវត្តគម្រោង ក្រសួងបានសង្កេតឃើញថា មានបញ្ហាមួយចំនួនបានជះឥទ្ធិពលដល់ការគ្រប់គ្រងថែទាំឧបករណ៍បរិក្ខារពេទ្យដូចជា ការកកស្ទះឧបករណ៍ចាស់ៗដែលខូចដែលមានការលំបាកក្នុងការជម្រះបញ្ជីចេញ ក្នុងនោះភាគច្រើនជាឧបករណ៍ដែលផ្តល់ជាអំណោយរបស់អង្គការ និងសប្បុរសជននានាដែលពុំមានការពិនិត្យត្រឹមត្រូវមុនពេលទទួលយក ជាឧបករណ៍ដែលបានខូចតាំងពីមុនពេលផ្តល់ឱ្យ និងខ្លះទៀតជាម៉ូដែលចាស់ខ្លាំងពេកដែលពុំមានសមាសភាព និងគ្រឿងបន្លាស់គ្រប់គ្រាន់ និងខ្លះទៀតពុំចាំបាច់សម្រាប់មន្ទីរពេទ្យ ។ យោងតាមស្ថានភាពខាងលើ ក្រសួងបានរៀបចំសេចក្តីណែនាំផ្នែកបច្ចេកទេសសម្រាប់ការទទួលយកឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ (Second hand medical equipment) សម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់ទទួលយកឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយដើម្បីឱ្យការប្រើប្រាស់ និងការថែទាំឧបករណ៍ បរិក្ខារពេទ្យទាំងនោះបានសមស្រប មានប្រសិទ្ធភាព និងសុវត្ថិភាព ។

ក្រសួងសុខាភិបាលសំណូមពរដល់មន្ទីរពេទ្យសាធារណៈ និងវិទ្យាស្ថាន មជ្ឈមណ្ឌលជាតិ និងអ្នកផ្តល់ជំនួយទាំងអស់ សូមអនុវត្តតាមសេចក្តីណែនាំនេះដោយយកចិត្តទុកដាក់ខ្ពស់បំផុត ។

ភ្នំពេញ ថ្ងៃទី 05 ខែ ៨ ឆ្នាំ ២០១១

**ជ. រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

សាស្ត្រាចារ្យ **អេង ហួត**

# មាតិកា

## ~ បញ្ជីពាក្យអក្សរកាត់

## ~ សេចក្ដីណែនាំសង្ខេប


I. គោលបំណងនៃសេចក្តីណែនាំ ············ ១

II. ប្រវត្តិ ············ ២

III. លក្ខណៈពិសេសនៃឧបករណ៍បរិក្ខារពេទ្យ ············ ៣

IV. គុណសម្បត្តិ និង គុណវិបត្តិនៃការទទួលឧបករណ៍បរិក្ខាពេទ្យដែលគេប្រើហើយ ············ ៨

V. លក្ខ័ខ័ណ្ឌដំបូងនៅពេលទទួលបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ············ ១៣

VI. បន្ទាប់ពីទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ············ ១៨

VII. ឯកសារយោង ············ ១៩


## ~ ឧបសម្ព័ន្ធៈ


ឧបសម្ព័ន្ធ-១: ករណីសិក្សាចំពោះការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ

ឧបសម្ព័ន្ធ-២: បញ្ជីត្រួតពិនិត្យតាមដំណាក់កាលនៃការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ

ឧបសម្ព័ន្ធ-៣: បញ្ជីនៃគ្រឿងបន្ទាប់បន្សំ គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ និងគ្រឿងបន្លាស់សម្រាប់ឧបករណ៍បរិក្ខារពេទ្យដែលចាំបាច់

ឧបសម្ព័ន្ធ-៤: បញ្ជីឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍បរិក្ខារពេទ្យក្នុងស្រុក

ឧបសម្ព័ន្ធ-៥: គម្រូអនុស្សរណៈនៃការយោគយល់គ្នាក្នុងការប្រគល់ឧបករណ៍បរិក្ខារពេទ្យ

ឧបសម្ព័ន្ធ-៦: ព័ត៌មាននៃឧបករណ៍បរិក្ខារពេទ្យ (សម្រាប់ទទួលយកឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ)

# បញ្ជីពាក្យអក្សរកាត់

| | | |
|---|---|---|
| AC | Alternative Current | ចរន្តឆ្លាស់ |
| CE | Communauté Européenne (European Community) | សញ្ញាសម្គាល់ផលិតផលរបស់សហគមន៍អឺរ៉ុប |
| CPA2 | Complementary Package of Activity Level 2 Hospital | មន្ទីពេទ្យបង្អែកកម្រិត ស.ស.ប ២ |
| CPA3/NH | Complementary Package of Activity Level 3 / National Hospital | មន្ទីរពេទ្យជាតិ និង មន្ទីរពេទ្យបង្អែកកម្រិត ស.ស.ប ៣ |
| CT | Computed Tomography | ម៉ាស៊ីនស្កែនដោយកាំរស្មីអ៊ិច |
| DC | Direct Current | ចរន្តជាប់ |
| ECG | Electrocardiograph | ឧបករណ៍តាមដានចលនាបេះដូង |
| HSD | Hospital Services Department | នាយកដ្ឋានមន្ទីរពេទ្យ |
| JICA | Japan International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន |
| JIS | Japan Industry Standard | បទដ្ឋានឧស្សាហកម្មនៃប្រទេសជប៉ុន |
| ME | Medical Equipment | ឧបករណ៍បរិក្ខារពេទ្យ |
| MEDEM-1 (MEDEM) | Project on Promotion of Medical Equipment Management System | គម្រោងលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ |
| MEDEMIS | MEDEM Inventory Software | កម្មវិធីគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌរបស់គម្រោង MEDEM |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| NGO | Non Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NWT | National Workshop Team | ក្រុមរោងជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ |
| $SPO_2$ | Saturated Percutaneous Oxygen | ប្រដាប់សម្រាប់វាស់កម្រិតអុកស៊ីហ្សែនក្នុងឈាម |
| VF | Ventricular Fibrillation | ការកន្ត្រាក់មិនប្រក្រតីនៃសរសៃសាច់ដុំរបស់ថតនៃបេះដូង |

# សេចក្តីណែនាំសង្ខេប

សេចក្តីណែនាំនេះត្រូវបានរៀបចំឡើងដើម្បីជៀសវាងទទួលយកប្រភពកាកសំណល់ក្នុងការនាំចូលឧបករណ៍បរិក្ខារពេទ្យមកប្រទេសកម្ពុជាដោយសារឧបករណ៍ទាំងនោះមិនមានប្រយោជន៍ក្នុងការផ្តល់សេវាដូចដែលក្រសួងសុខាភិបាលធ្លាប់មានបទពិសោធន៍ពីមុនមក ។ មានករណីជាច្រើនបានកើតឡើងដូចជា ÷

ឧបករណ៍ផ្តល់ជំនួយជាឧបករណ៍ដែល ÷

ក. មិនចាំបាច់សម្រាប់មន្ទីរពេទ្យទទួលក្នុងផ្តល់សេវាគ្លីនិក

ខ. មានស្ថានភាពមិនសមស្រប ( ម៉ូដែលចាស់ ឧបករណ៍ចាស់មិនសមស្របយ៉ាប់យ៉ឺន)

គ. មិនដំណើរការមុនពេលប្រគល់ជូន

ឃ. មិនមានសមាសភាពផ្សំគ្រប់ចំនួន ( មិនមានភ្ជាប់មកជាមួយនូវគ្រឿងបន្ទាប់បន្សំ និងគ្រឿងប្រើប្រាស់ប្រចាំថ្ងៃចាំបាច់ ជាដើម)

ង. គ្មានឯកសារណែនាំផ្នែកបច្ចេកទេស

ច. គ្មានក្រុមហ៊ុនផ្តល់សេវាកម្មក្នុងស្រុក

គ្រប់ឧបករណ៍បរិក្ខារពេទ្យទាំងអស់ត្រូវមានលក្ខណៈសមស្របតាមតម្រូវការគ្លីនិក និងអនុលោមតាមបទដ្ឋានឧបករណ៍បរិក្ខារពេទ្យ ។

ការផ្តល់ជំនួយឧបករណ៍បរិក្ខារពេទ្យមានប្រយោជន៍លុះត្រាតែមានការទំនាក់ទំនង និងប្រឹក្សាយោបល់រវាង ភ្នាក់ងារផ្តល់ជំនួយនិងមន្ទីរពេទ្យទទួល ចាប់តាំងពីដំណាក់កាលដំបូងរហូតដល់មានការយល់ព្រមគ្នាទៅវិញទៅមក ។ អាស្រ័យហេតុនេះ ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជាបានកំណត់ថារាល់ការផ្តល់ជំនួយឧបករណ៍បរិក្ខារពេទ្យ (ឧបករណ៍ដែលគេប្រើហើយ) ដល់ប្រទេសកម្ពុជាអាចទទួលយកបានលុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌដំបូងដែលមាន រៀបរាប់ក្នុងទំព័រទី ១៣ ។

ក្រសួងសុខាភិបាលសូមបញ្ជាក់ថាក្រសួងនឹងមិនទទួលយកឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយទេជាពិសេស ឧបករណ៍ទាំងឡាយណាដែលមានល័ក្ខខ័ណ្ឌអប្បបរមាចំនួនពីរដូចខាងក្រោម:

១) ក្រសួងសុខាភិបាលមិនទទួលយកឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយជាង ៦ឆ្នាំ គិតចាប់ពីពេលផលិតឧបករណ៍ ( សូមបញ្ជាក់ថា អាយុកាលរបស់ឧបករណ៍ទាំងនោះមានប្រហែល ៦ឆ្នាំ បើតាមការកំណត់ទូទាំងសកលលោក និងបទដ្ឋានអន្តរជាតិដែលគាំទ្រការកំណត់នេះ) ។ អាស្រ័យហេតុនេះភាគីផ្តល់ជំនួយគួរផ្តល់ព័ត៌មានជាមូលដ្ឋានទាក់ទងនឹងឧបករណ៍បរិក្ខារពេទ្យ យ៉ាងហោចណាស់ម៉ូដែល និងថ្ងៃខែឆ្នាំផលិតមុនពេលប្រគល់ឧបករណ៍ជូនមន្ទីរពេទ្យ ។

២) ក្រសួងសុខាភិបាលមិនទទួលយកឧបករណ៍បរិក្ខារពេទ្យដែលមានស្ថានភាពដំណើរការ “មិនដំណើរការ” មុនពេលផ្តល់ជំនួយទេ ។ ដូច្នេះ ភាគីផ្តល់ជំនួយត្រូវពិនិត្យនិងបញ្ជាក់អំពីស្ថានភាពដំណើរការរបស់ឧបករណ៍ ព្រមទាំងរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើតេស្តនេះ ។

## I. គោលបំណងនៃសេចក្តីណែនាំ

គោលបំណងនៃសេចក្តីណែនាំនេះគឺដើម្បីធានាថាគ្រប់មន្ទីរពេទ្យសាធារណៈទាំងអស់នៅទូទាំងប្រទេស ដែលបានទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ អាចប្រើប្រាស់ឧបករណ៍នោះបានយ៉ាងសមស្របប្រកប ដោយប្រសិទ្ធផល និងសុវត្ថិភាព។ សេចក្តីណែនាំនេះមិនគ្របដណ្តប់លើសំភារៈពេទ្យតូចតាច សង្ហារឹមពេទ្យ និង គ្រឿងប្រើប្រាស់ប្រចាំថ្ងៃទេ។ ជាទូទៅ ឧបករណ៍វេជ្ជសាស្ត្រចែកចេញជាច្រើនប្រភេទផ្សេងៗគ្នាដូចមានរៀបរាប់ នៅក្នុងប្រអប់ទី-១:

**ប្រអប់ទី-១: ប្រភេទឧបករណ៍ពេទ្យវេជ្ជសាស្ត្រ**

**១. គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ** (សម្ភារៈបរិក្ខារប្រើតែម្តងរួចទុកដាក់ក្នុងប្រអប់សុវត្ថិភាពជៀសវាង ការចម្លងរោគមុននឹងយកទៅដុត : ម្ជុល ស៊ីរ៉ាំង ស្បៃ ។ល។)





**២. សំភារៈពេទ្យតូចតាច** (មិនទាមទារការថែទាំ : កន្ត្រៃ កាំបិតវះ ចាន ។ល។)





**៣. សង្ហារឹមពេទ្យ** (ងាយស្រួលការថែទាំ : គ្រែអ្នកជំងឺ រទេះរុញ ។ល។)






**៤. ឧបករណ៍បរិក្ខារពេទ្យ** (ទាមទារការថែទាំសមស្របៈ ម៉ាស៊ីនថត-ឆ្លុះដោយកាំរស្មីអ៊ិច

ម៉ាស៊ីនញែកសូលុយស្យុង ទូរក្សាកំដៅប្រើក្នុងមន្ទីរពិសោធន៍ ម៉ាស៊ីនពិនិត្យចង្វាក់បេះដូង ។ល។)





**សេចក្តីណែនាំនេះគ្របដណ្តប់លើឧបករណ៍បរិក្ខារពេទ្យតែប៉ុណ្ណោះ**

សេចក្តីណែនាំនេះមានពន្យល់ពីលក្ខណៈ និងលទ្ធភាពរបស់ឧបករណ៍បរិក្ខារពេទ្យដើម្បីឱ្យការគ្រប់គ្រងបាន សមស្របនៅតាមមន្ទីរពេទ្យ ។ សេចក្តីណែនាំនេះត្រូវបានបង្កើតឡើង និង ទទួលស្គាល់ជាផ្លូវការ ថាជាលក្ខខ័ណ្ឌ បច្ចេកទេសដំបូងមួយដែលត្រូវបំពេញនៅពេលទទួលឧបករណ៍បរិក្ខារពេទ្យ ដែលគេប្រើហើយ ដើម្បីជៀសវាង ផលលំបាកផ្សេងៗ ដែលអាចកើតមានឡើងជុំវិញការទទួលយកឧបករណ៍បរិក្ខារពេទ្យ ។

នៅទីបញ្ចប់ ក្រសួងសុខាភិបាលសង្ឃឹមថាឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយនឹងត្រូវបានយកទៅ ប្រើប្រាស់ក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខមាលភាពរបស់ប្រជាជនកម្ពុជាតាមរយៈការបង្កើនគុណភាពសេវា វេជ្ជសាស្ត្រនៅតាមមន្ទីរពេទ្យនីមួយៗ និងរំពឹងថាអាចរក្សាបាននូវចំណងមិត្តភាពដ៏ល្អជាមួយអង្គភាពផ្តល់ជំនួយ ទាំងអស់ ។

## II. ប្រវត្តិ

គួរពិចារណាទៅលើប្រវត្តិមួយចំនួនដូចខាងក្រោមនៅពេលដែលប្រទេសកម្ពុជាមានគម្រោងទទួល និង ប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ :

### ១. ភាគីផ្តល់ជំនួយ

ជាទូទៅ នៅពេលដែលម្ចាស់ជំនួយធ្វើការពិនិត្យនិងជួយដល់ប្រទេសដែលកំពុងអភិវឌ្ឍនានា ពួកគេភាគច្រើនសង្កេតឃើញថា ការផ្តល់សេវាវេជ្ជសាស្ត្រជូនប្រជាជនក្នុងតំបន់នៅមិនទាន់បានសមស្រប នៅឡើយដោយសារមានការខ្វះខាតឧបករណ៍បរិក្ខារពេទ្យ ។ ឧបករណ៍ទាំងនោះចាំបាច់ណាស់ដើម្បីផ្តល់ សេវាវេជ្ជសាស្ត្រជូនប្រជាជនក្នុងតំបន់ឱ្យបានសមស្រប ។ ប៉ុន្តែបើតាមភាពជាក់ស្តែង ភ្នាក់ងារផ្តល់សេវា វេជ្ជសាស្ត្រភាគច្រើនមិនមានថវិកាគ្រប់គ្រាន់ដើម្បីទិញឧបករណ៍ថ្មីៗបានតាមតម្រូវការឡើយ ។ ដូច្នោះ ហើយបានជាអ្នកផ្តល់ជំនួយចង់ផ្តល់ជូននូវឧបករណ៍ចាំបាច់តាមលទ្ធភាពរបស់ពួកគាត់ ។ ទោះបីជាម្ចាស់ ជំនួយមានបំណងចង់ផ្តល់ឧបករណ៍ថ្មី ប៉ុន្តែថវិការបស់គាត់មានកម្រិត ។

មានប្រទេសផ្តល់ជំនួយខ្លះត្រូវការចំណាយច្រើន ដើម្បីជម្រះបញ្ជីឧបករណ៍បរិក្ខារពេទ្យជា ផ្លូវការ ។ ឧបករណ៍ដែលមានដំណើរការល្អត្រូវបោះចោល ហើយត្រូវចំណាយលុយបន្ថែមទៀតសម្រាប់ ធ្វើការជម្រះបញ្ជី ។ ដើម្បីចៀសវាងបញ្ហានេះ អ្នកផ្តល់ជំនួយខ្លះបានផ្តល់ឧបករណ៍ដែលអាចប្រើប្រាស់បាន ដល់អ្នកដែលត្រូវការប្រើប្រាស់ឧបករណ៍នោះតទៅទៀត ។ វិធានការនេះគឺជាគោលនយោបាយមួយដ៏ មានប្រសិទ្ធភាពក្នុងការថែរក្សាបរិស្ថានផងដែរ ។

### ២. ភាគីទទួលជំនួយ

ស្ទើរតែគ្រប់មន្ទីរពេទ្យសាធារណៈទាំងអស់ក្នុងប្រទេសកម្ពុជាមានការខ្វះខាតឧបករណ៍ បរិក្ខារពេទ្យ និងអគារដើម្បីផ្តល់សេវាវេជ្ជសាស្ត្រចាំបាច់ជូនប្រជាជនកម្ពុជាឱ្យបានសមស្របទៅតាម

កម្រិតដែលបានរំពឹងទុក ។ ដោយសារស្ថានភាពបែបនេះ វាជាឱកាសមួយដ៏ល្អក្នុងការបំពេញបន្ថែមនូវការខ្វះខាតឧបករណ៍បរិក្ខារពេទ្យនៅក្នុងមន្ទីរពេទ្យ ។ មានមន្ទីរពេទ្យភាគច្រើនត្រូវការអគារ និងឧបករណ៍បរិក្ខារពេទ្យដើម្បីផ្តល់សេវាវេជ្ជសាស្ត្រជូនប្រជាជនកម្ពុជាឱ្យបានសមស្រប ។

ជាមួយគ្នានេះដែរ ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គភាពផ្តល់ជំនួយនានាដែលមានបំណងជួយឧបត្ថម្ភនូវការខ្វះខាតទាំងនេះ និងឆន្ទៈក្នុងការបន្តទំនាក់ទំនងល្អតទៅអនាគត ។

## III. លក្ខណៈពិសេសនៃឧបករណ៍បរិក្ខារពេទ្យ

នៅពេលគិតដល់ការប្រើប្រាស់និងការថែទាំឧបករណ៍បរិក្ខារពេទ្យ ចាំបាច់ត្រូវដឹងថាវាមានលក្ខណៈខុសពីយានយន្ត ឬទោចក្រយានយន្តផ្សេងៗ ។

ក្នុងវិស័យវេជ្ជសាស្ត្រទំនើប ម៉ូដែលឧបករណ៍បរិក្ខារពេទ្យមានការកើនឡើងជាលំដាប់ទៅតាមចំនួននៃការធ្វើរោគវិនិច្ឆ័យ ការពិនិត្យ និងការព្យាបាល ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ គួកត់សម្គាល់ថាម៉ូដែលរបស់ឧបករណ៍បរិក្ខារពេទ្យមានចំនួនប្រហែល ៣០.០០០ ។ ផ្ទុយទៅវិញម៉ូដែលរបស់យានយន្ត និង ទោចក្រយានយន្តមានចំនួនប្រហែល ៣០០ និង ៦០០ អាស្រ័យទៅតាមប្រភេទនីមួយៗ ។ ការប្រៀបធៀបនេះបានបង្ហាញឱ្យឃើញពីភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងម៉ូដែលរបស់ឧបករណ៍បរិក្ខារពេទ្យ និង យានយន្តនិងទោចក្រយានយន្ត ។

ករណីឧបករណ៍បរិក្ខារពេទ្យស្ថិតក្រោមស្ថានភាពប្រើប្រាស់ យើងអាចដឹងពីមុខងារ និង លទ្ធភាពដំណើរការរបស់វាបានទៅតាមលក្ខណៈទាំងបួនដូចខាងក្រោមនេះ :

### ១. ភាពអាចទុកចិត្តបាន

គោលបំណងសំខាន់របស់ឧបករណ៍បរិក្ខារពេទ្យគឺដើម្បីធ្វើរោគវិនិច្ឆ័យ ពិនិត្យ និងព្យាបាលជំងឺ ។ ដូច្នេះហើយ នៅពេលដែលយើងត្រូវការធ្វើសកម្មភាពណាមួយដូចខាងលើ ឧបករណ៍បរិក្ខារពេទ្យគួរតែត្រៀមរួចជាស្រេចសម្រាប់ប្រើប្រាស់ ។ មានឧទាហរណ៍មួយដូចខាងក្រោមទាក់ទងនឹងបញ្ហាកើតឡើងនៅពេលប្រើប្រាស់ម៉ាស៊ីនកន្ត្រាក់បេះដូង :

ម៉ាស៊ីនកន្ត្រាក់បេះដូង គឺសម្រាប់ប្រើប្រាស់ចំពោះអ្នកជំងឺដែលមានចង្វាក់បេះដូងមិនប្រក្រតី (ហៅកាត់ថា “VF”) គាំងបេះដូង ។ ឧបករណ៍នេះបានបង្កើតឡើងដោយធ្វើឱ្យមានលក្ខណៈឆក់អគ្គិសនីក្នុងរយៈពេលខ្លីដើម្បីឱ្យបេះដូងអ្នកជំងឺអាចដំណើរការ និងមានជីពចរធម្មតាឡើងវិញ ។




រូបភាព ១: ឧទាហរណ៍អំពីគ្រោះថ្នាក់មួយដែលកើតឡើងពេលប្រើម៉ាស៊ីនកន្ត្រាក់បេះដូង

បុរសម្នាក់គាំងបេះដូង ហើយបានដួលដេកផ្ងារ (គាត់អាចមានចង្វាក់បេះដូង មិនប្រក្រតី)។ ប្រាំនាទីក្រោយមក ក្រុមជួយសង្គ្រោះបានបើកឡានសង្គ្រោះបន្ទាន់មកដល់។ គាត់បានព្យាយាមប្រើម៉ាស៊ីនកន្ត្រាក់បេះដូង។ ប៉ុន្តែបន្ទះអេឡិចត្រូតរបស់ម៉ាស៊ីននោះផ្តល់ភ្លើងមិនគ្រប់គ្រាន់ដោយសារតែវាមិនបានសាកភ្លើង។ ជាលទ្ធផលបុរសនោះបានស្លាប់។

ករណីខាងលើនេះបានបង្ហាញយ៉ាងច្បាស់ថាប្រសិនបើមានការថែទាំឧបករណ៍បានត្រឹមត្រូវបុរសម្នាក់នោះប្រហែលជាអាចរស់បានរហូតដល់សព្វថ្ងៃនេះ។ នេះបញ្ជាក់យ៉ាងច្បាស់ថាអាទិភាពមួយក្នុងចំណោមអាទិភាពចម្បង២របស់ឧបករណ៍បរិក្ខារពេទ្យគឺតម្រូវឱ្យមានភាពអាចទុកចិត្តបាន។

## ២. ភាពត្រឹមត្រូវ

ឧបករណ៍បរិក្ខារពេទ្យខ្លះត្រូវបានប្រើប្រាស់ក្នុងគោលបំណងធ្វើរោគវិនិច្ឆ័យ និងពិនិត្យដើម្បីទទួលបានលទ្ធផលនៃការវិភាគទិន្នន័យ (ឧទាហរណ៍ដូចជាឧបករណ៍តាមដានចលនាបេះដូង (ECG) ម៉ាស៊ីនអេកូ ឧបករណ៍មន្ទីរពិសោធន៍ ជាដើម)។ ប្រសិនបើទិន្នន័យទាំងនោះមានកំហុស វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក-យិកាអាចធ្វើការព្យាបាលខុសដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អ្នកជំងឺព្រមទាំងផ្ទុយពីបំណងដែលអ្នកជំងឺចង់បាន។

យោងតាមស្ថានភាពខាងលើ យើងមិនគួរឱ្យមានលទ្ធផលខុសកើតឡើងទេ។ ហេតុដូច្នេះ ចំណុចសំខាន់ឧបករណ៍បរិក្ខារពេទ្យត្រូវតែផ្តល់លទ្ធផលនៃការវិភាគឱ្យបានត្រឹមត្រូវ។

ឧទាហរណ៍អ្នកជំងឺម្នាក់ដែលសង្ស័យថាលើសជាតិសូដ្យូម (សូដ្យូមក្នុងឈាមមានកម្រិតខ្ពស់) បានទៅមន្ទីរពេទ្យដើម្បីធ្វើការវិភាគជាតិអេឡិចត្រូលីតនៅក្នុងឈាម ។ នៅក្នុងករណីលើសជាតិសូដ្យូម តម្លៃសូដ្យូមនៅក្នុងឈាមអាចលើសពី ១៥០mEq/L ។ ប៉ុន្តែតម្លៃពិតនៃលទ្ធផលវិភាគក្នុងករណីនេះគឺ ១៤១.៣mEq/L ។ វេជ្ជបណ្ឌិតជឿជាក់លើតម្លៃនេះ ហើយបានសន្និដ្ឋានថាអ្នកជំងឺមានអត្រាសូដ្យូមធម្មតា ។ ដូច្នោះ លទ្ធផលនៃការធ្វើរោគវិនិច្ឆ័យនេះហាក់ដូចជាមិនមានបញ្ហាអ្វីទេចំពោះអ្នកជំងឺ ។ ប៉ុន្តែប៉ុន្មានថ្ងៃក្រោយមកស្ថានភាពអ្នកជំងឺប្រែប្រួលទៅជាធ្ងន់ធ្ងរហួតដល់ខ្វះជាតិទឹកយ៉ាងខ្លាំង ។ គាត់ត្រូវបានបញ្ជូនទៅកាន់អគារសង្គ្រោះបន្ទាន់ ។

បញ្ហានេះបណ្ដាលមកពីឧបករណ៍វិភាគគ្មានភាពត្រឹមត្រូវ ។ យោងតាមស្ថានភាពនេះអ្នកបច្ចេកទេសមន្ទីរពិសោធន៍ជានិច្ចជាកាលត្រូវធ្វើការត្រួតពិនិត្យស្ថានភាព និងគុណភាពរបស់ឧបករណ៍ឱ្យបានសមស្រប ។




រូបភាព-២: ឧទាហរណ៍អំពីឧបករណ៍ដែលបង្ហាញលទ្ធផលមិនបានត្រឹមត្រូវ

## ៣. សុវត្ថិភាព

ឧទាហរណ៍អំពីមនុស្សម្នាក់ដែលបានស្លាប់ដោយសារគ្រោះថ្នាក់បណ្ដាលមកពីឧបករណ៍បរិក្ខារ-ពេទ្យគ្មានសុវត្ថិភាព:

គិលានុបដ្ឋាយិកាម្នាក់បានរៀបចំត្រួតពិនិត្យមុខងាររបស់ម៉ាស៊ីនតាមដានចលនាបេះដូង (ECG) ដែលមានម៉ូដែលអាយុជាង ១០ឆ្នាំហើយ ។ នាងបានដោតឌុយភ្លើង ហើយចុចកុងតាក់ដំណើរការ

ឧបករណ៍ដូចមានបង្ហាញក្នុងរូបខាងក្រោម ។ បន្ទិចក្រោយមកចរន្តជ្រាបរបស់តួឧបករណ៍បានឆ្លងតាមរយៈដៃរបស់នាងចូលដល់បេះដូង ( គិលានុបដ្ឋាយិការូបនេះបានកាន់ម៉ាស៊ីនដោយផ្ទាល់ដៃទាំងពីររបស់នាង) ។ ក្រោយមកនាងបានស្លាប់ដោយសារការគាំងបេះដូង ។

ករណីនេះកើតឡើងដោយសារតែម៉ាស៊ីនមានអាយុចាស់ពេក ហើយស្ថានភាពនៃការរុំខ្សែភ្លើងនៅក្នុងសៀគ្វីអគ្គិសនីមិនបានល្អដែលបានបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិត ។




រូបភាព ៣: ឧទាហរណ៍អំពីគ្រោះថ្នាក់មួយដែលកើតឡើងដោយសារ
ចរន្តលេចជ្រាបរបស់ឧបករណ៍បរិក្ខារពេទ្យ

យោងតាមករណីខាងលើ យើងអាចយល់បានថាឧបករណ៍បរិក្ខារពេទ្យអាចបណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ដូចជាការឆក់អគ្គិសនី និងបញ្ហាអវិជ្ជមានជាច្រើនទៀត ដោយសារតែតួឧបករណ៍អាចត្រូវបានប៉ះផ្ទាល់ជាមួយស្បែក ឬសរីរាង្គរបស់មនុស្សតាមរយៈមុខកាត់មួយចំនួន ដូចជាអេឡិចត្រូតឧបករណ៍បញ្ជូន និងទទួលសញ្ញា (Probe, Transducer) ជាដើម ។

ដូច្នេះគ្រប់ឧបករណ៍បរិក្ខារពេទ្យត្រូវតែមានសុវត្ថិភាពជាចម្បងមុននឹងប្រើប្រាស់ ។

## ៤. ការថែទាំ

ផ្អែកតាមស្ថានភាពខាងលើ ការថែទាំឱ្យបានសមស្របពិតជាមានសារៈសំខាន់ណាស់ ( ការថែទាំបង្ការ និងការជួសជុលតូចតាច) ដើម្បីឱ្យឧបករណ៍បរិក្ខារពេទ្យមានភាពអាចទុកចិត្តបាន ភាពត្រឹមត្រូវ

និងសុវត្ថិភាព នៅពេលប្រើប្រាស់ ។ ប៉ុន្តែ វាមានការលំបាកក្នុងការថែទាំឧបករណ៍បរិក្ខារពេទ្យ ។ ការថែទាំឧបករណ៍បរិក្ខារពេទ្យមិនអាចធ្វើទៅបានដោយរលូន សមស្រប និងប្រកបដោយប្រសិទ្ធភាពទេ ប្រសិនបើយើងមិនគិតដល់ចំណុចទាំងបីខាងក្រោមនេះ :

**ក. ភាពលំបាកនៃការជួសជុល**

ដូចដែលបានរៀបរាប់ខាងលើរួចមកហើយ ( ក្នុងលេខរៀង ៣: លក្ខណៈពិសេសរបស់ឧបករណ៍បរិក្ខារពេទ្យ) ឧបករណ៍បរិក្ខារពេទ្យមានម៉ូដែលច្រើនប្រភេទបើប្រៀបធៀបនឹងយានយន្ត ឬទោចក្រយានយន្ត ដែលធ្វើឱ្យការជួសជុលក៏មានការលំបាកផងដែរ ។ បញ្ហាដ៏សំខាន់មួយដែលយើងកំពុងជួបប្រទះគឺការខ្វះខាតធនធានមនុស្សក្នុងប្រទេសកម្ពុជា ( អ្នកបច្ចេកទេស ឬវិស្វករ ដែលអាចធ្វើការវិនិច្ឆ័យ និងជួសជុលបាន) និងការលំបាកក្នុងការរកទិញគ្រឿងបន្លាស់ ។

**ខ. ចំណាយអប្បបរមាសម្រាប់ការថែទាំ**

ការថែទាំឧបករណ៍បរិក្ខារពេទ្យត្រូវធ្វើឡើងដោយទៀងទាត់ ប៉ុន្តែវាក៏ត្រូវការចំណាយជាប្រចាំដែរ ។

**① ការផ្លាស់ប្តូរគ្រឿងបន្លាស់**

ដើម្បីឱ្យឧបករណ៍បរិក្ខារពេទ្យអាចរក្សាបាននូវស្ថានភាពល្អ ចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរផ្នែកដែលសឹករិចរិល និងផ្នែកដែលខូចតាមពេលកំណត់ ។ គ្រឿងបន្លាស់ទាំងនោះមានដូចជា តម្រងមីក្រូរបស់កៃវិចញ្ញឹមទារក តម្រងទឹកឧបករណ៍រំងាប់មេរោគ និងអំពូលវះកាត់ ជាដើម ។

**② លទ្ធកម្មគ្រឿងប្រើប្រាស់ប្រចាំថ្ងៃ**

ជាពិសេសចំពោះឧបករណ៍មន្ទីរពិសោធន៍ត្រូវទិញគ្រឿងប្រើប្រាស់ប្រចាំថ្ងៃជាប្រចាំ ដើម្បីឱ្យការប្រើប្រាស់បានសមស្រប ។ គ្រឿងប្រើប្រាស់ប្រចាំថ្ងៃទាំងនោះមានដូចជា សំភារៈប្រតិករ និងសូលុយស្យុងសម្រាប់សម្អាតជាដើម ។

**③ ការចុះកិច្ចសន្យាការថែទាំជាមួយក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍បរិក្ខារពេទ្យ (ភ្នាក់ងារក្នុងស្រុក)**

ប្រសិនបើមន្ទីរពេទ្យមានប្រើឧបករណ៍បរិក្ខារពេទ្យទំនើបៗ ដូចជា CT ស្កេន ប្រព័ន្ធម៉ាស៊ីនថត-ឆ្លុះកាំរស្មីអ៊ិចឌីជីថល និងម៉ាស៊ីនវិភាគគីមីសាស្ត្រ មន្ទីរពេទ្យទាំងនោះគប្បីចុះកិច្ចសន្យាថែទាំឧបករណ៍តាមពេលកំណត់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍ ព្រោះវាត្រូវការថែទាំដោយអ្នកឯកទេសដែលមានជំនាញជាក់លាក់ (Bio-medical Engineer) ។

**គ. ចំណេះដឹង និងបច្ចេកទេសចាំបាច់**

ដើម្បីធ្វើការថែទាំឧបករណ៍បរិក្ខារពេទ្យឱ្យបានសមស្រប ចាំបាច់ត្រូវធានាឱ្យមានធនធានមនុស្សដែលមានចំណេះដឹង និងបច្ចេកទេសផ្នែកជីវវិស្វកម្មវេជ្ជសាស្រ្ត។ មូលហេតុនៃតម្រូវការនេះគឺដោយសារមានការលំបាកក្នុងការសិក្សារចនាសម្ព័ន្ធ មេកានិច និងគោលការណ៍ប្រើប្រាស់ឧបករណ៍គ្រប់ម៉ូដែល និងគ្រប់ប្រភេទ។ មានតែអ្នកឯកទេសទេដែលមានចំណេះដឹងទាំងនោះ និងអាចធ្វើការថែទាំឧបករណ៍បរិក្ខារពេទ្យប្រកបដោយសុវត្ថិភាព និងអាចទុកចិត្តបាន។ យោងតាមការរៀបរាប់ខាងលើ ឧបករណ៍បរិក្ខារពេទ្យមានលក្ខណៈពិសេសជាច្រើន ដូច្នេះដើម្បីលើកដាក់វាឱ្យបានសមស្របចាំបាច់ត្រូវមានចំណេះដឹង និងជំនាញបច្ចេកទេសគ្រប់គ្រាន់។

## IV. គុណសម្បត្តិ និងគុណវិបត្តិនៃការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ

តាមរបាយការណ៍ជាច្រើនបានឱ្យដឹងថាការទទួលយកឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយបានផ្តល់គុណសម្បត្តិ និងគុណវិបត្តិជាច្រើនដូចខាងក្រោមៈ

### ១. គុណសម្បត្តិ

**ក. ចំណាយដំបូងតិចជាងឧបករណ៍ថ្មី**

ការទិញឧបករណ៍ថ្មី ជាធម្មតាត្រូវចំណាយថវិកាច្រើន ហើយបន្ទាប់ពីធ្វើលទ្ធកម្មចាំបាច់ត្រូវការថវិកាបន្ថែមទៀតសម្រាប់ទិញសំភារៈដំឡើងឧបករណ៍ព្រមទាំងកិច្ចសន្យាថែទាំផងដែរ។ ប៉ុន្តែ ប្រសិនបើទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ចំណាយដំបូងនឹងត្រូវបានកាត់បន្ថយ។

**ខ. ពង្រឹងទំនាក់ទំនងជាមួយអង្គភាពផ្តល់ជំនួយ**

តាមរយៈការផ្តល់ជំនួយឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ប្រទេសកម្ពុជាអាចមានឱកាសបង្កើតទំនាក់ទំនងដ៏ល្អជាមួយអង្គភាពផ្តល់ជំនួយនានានៅពេលអនាគត។ ទំនាក់ទំនងនេះមិនត្រឹមតែការផ្តល់ជំនួយឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយប៉ុណ្ណោះទេ ប៉ុន្តែអាចជាកិច្ចសហប្រតិបត្តិការ ឬការឧបត្ថម្ភគាំទ្រផ្សេងៗទៀតដូចជា កិច្ចសហប្រតិបត្តិការបច្ចេកទេសផ្នែកគ្លីនិក ក៏ដូចជាជំនាញក្នុងការគ្រប់គ្រងមន្ទីរពេទ្យ។ ទំនាក់ទំនងនេះអាចផ្តល់ផលប្រយោជន៍ជាច្រើនដល់ភាគីទទួលជំនួយ (ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជា)។

**២.គុណវិបត្តិ**

**ក. គ្មានការធានារ៉ាប់រង**

ក្នុងករណីទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ គ្មានការធានារ៉ាប់រងក្នុងការផ្គត់ផ្គង់គ្រឿងបន្ទាប់បន្សំ គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ និងគ្រឿងបន្លាស់ពីរោងចក្រផលិតទេ ។

ឧទាហរណ៍ដូចជា មានមន្ទីរពេទ្យខ្លះធ្លាប់មានបទពិសោធន៍ទទួលឧបករណ៍បរិក្ខារពេទ្យពីអង្គភាពផ្តល់ជំនួយ ប៉ុន្តែមិនមានភ្ជាប់មកជាមួយនូវគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់សម្រាប់ប្រើប្រាស់ជាមួយឧបករណ៍នោះ ។ ទោះបីជាមន្ទីរពេទ្យទាំងនោះខិតខំស្វែងរកគ្រឿងបន្ទាប់បន្សំ ឬ គ្រឿងបន្លាស់ពីក្រុមហ៊ុនក្នុងស្រុក ប៉ុន្តែភាគច្រើនរកមិនបាន ។ ជាលទ្ធផល មន្ទីរពេទ្យមិនអាចប្រើម៉ាស៊ីននោះបានទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត ។

**ខ. ងាយខូច បាក់បែក និងមានអាយុកាលប្រើប្រាស់ខ្លីជាងឧបករណ៍បរិក្ខារពេទ្យថ្មី**

ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើអស់រយៈពេលជាច្រើនឆ្នាំហើយ ងាយខូចឬបាក់បែកជាងឧបករណ៍បរិក្ខារពេទ្យថ្មី ។ ជាក់ស្តែងចំពោះផ្នែកដែលអាចចល័តបានរបស់វាមានសភាពចាស់ទ្រុឌទ្រោម និងសឹករិចរិលបន្តិចម្តងៗអាស្រ័យទៅតាមពេលវេលានៃការប្រើប្រាស់ ។

ក្នុងផ្នែកវិស្វកម្ម មានទ្រឹស្តីវិទ្យាសាស្ត្រមួយបានលើកឡើងថាគ្រប់ឧបករណ៍ទាំងអស់នឹងខូចក្នុងអំឡុងពេលនៃអាយុកាលរបស់វា ទោះបីជាវាដំណើរការធម្មតាក៏ដោយ ។ នៅពេលដែលជិតអស់អាយុកាលប្រើប្រាស់ ឧបករណ៍បរិក្ខារពេទ្យមានស្ថានភាពដំណើរការផ្លាស់ប្តូរមិនទៀងទាត់ ជួនកាលអាចប៉ះពាល់ដល់សុវត្ថិភាពអ្នកជំងឺ និងផ្អាកដល់ដំណើរសេវាកម្មផងដែរ ។

យោងតាមទ្រឹស្តីវិស្វកម្ម អត្រាកំហូចរបស់ឧបករណ៍អាចតាងដោយខ្សែកោងមួយ (ដែលមានរាងដូចអាងងូតទឹក) ។




រូបភាព-៤: រាងកោងរបស់អាងងូតទឹកដែលតំណាងឱ្យអត្រាកំហូចរបស់ឧបករណ៍

កំហូចឧបករណ៍អាចចែកចេញជាបីដំណាក់កាលតាមអត្រាកំហូចជាមូលដ្ឋាន ។ ខាងក្រោមមានរៀបរាប់សង្ខេបអំពីដំណាក់កាលនីមួយៗ:

### ① អំឡុងពេលនៃកំហូចដំបូង

ដូចមានបង្ហាញក្នុងរូបភាព-៤ ខាងលើ អត្រាកំហូចឡើងខ្ពស់ក្នុងដំណាក់កាលប្រើប្រាស់ដំបូង ។ បញ្ហានេះអាចកើតមានឡើងបន្ទាប់ពីការផលិតឧបករណ៍ភ្លាម (ខ្សែកោង (AB)) ដោយសារតែការរៀបចំសៀគ្វីមិនបានល្អ ការជ្រើសរើសធាតុផ្សំមិនសមស្រប និងកំហុសឆ្គងនៃដំណើរការផលិត ។ល ។ ទោះជាយ៉ាងក៏ដោយ ភាពខ្វះចន្លោះទាំងនេះប្រហែលជាមិនអាចរកឃើញដោយអ្នកប្រើប្រាស់ទេ ពីព្រោះវាត្រូវបានសង្កេត និងកែតម្រូវរួចហើយនៅពេលធ្វើតេស្តសាកល្បង ពេលធ្វើការត្រួតពិនិត្យក្នុងពេលនិងក្រោយពេលផលិតឧបករណ៍ ឬក្នុងពេលដំឡើងឧបករណ៍ដំបូង ។ នាពេលថ្មីៗនេះអត្រាកំហូចរបស់ឧបករណ៍មិនសូវខ្ពស់ដូចក្នុងខ្សែកោង (AB) ទេ ចាប់តាំងពីរោងចក្រផលិតឧបករណ៍បានពង្រឹងការគ្រប់គ្រងដំណើរការផលិតយ៉ាងហ្មត់ចត់ដើម្បីធានាឱ្យមានភាពត្រឹមត្រូវ និងភាពអាចទុកចិត្តបាននូវសមាសភាពទាំងឡាយដែលប្រើក្នុងឧបករណ៍ ក៏ដូចជាការផ្គុំឧបករណ៍ពេលផលិត ។

### ② អំឡុងពេលកំហូចដោយចៃដន្យ

បន្ទាប់ពីពេលប្រើប្រាស់ឧបករណ៍ដំបូងរហូតដល់ប្រើប្រាស់បានពាក់កណ្ដាល ស្ថានភាពរបស់វាហាក់ដូចជាមានលំនឹង ។ កំហូចនៃឧបករណ៍កម្រកើតមានណាស់ក្នុងអំឡុងពេលនេះ (ខ្សែកោង (BC)) ។ ប្រសិនបើមានកំហូចណាមួយកើតឡើងក្នុងកំឡុងពេលនេះ គឺវាកើតឡើងដោយចៃដន្យ ។

### ③ អំឡុងពេលកំហូចដោយការសឹករិចរិល

ខ្សែកោង (CD) បង្ហាញពីស្ថានភាពឧបករណ៍ចាស់ ។ ក្នុងអំឡុងពេលនេះអត្រាកំហូចចាប់ផ្ដើមកើនឡើងជាលំដាប់ដោយសារតែឧបករណ៍ចាស់ ការសឹករិចរិល ឬការបាក់បែកសមាសភាពផ្សំខាងក្នុងឧបករណ៍ ។ ទោះជាយ៉ាងណាក៏ដោយក៏អត្រាកំហូចនេះអាចកាត់បន្ថយបានដែរដោយការផ្លាស់ប្ដូរសមាសភាពដែលចាស់ ឬខូចចេញ និងការកែតម្រូវឱ្យបានសមស្របក្នុងពេលថែទាំ (អត្រាកំហូចអាចថយចុះដូចខ្សែកោង (CE)) ។

នៅពេលដែលមានប្រព័ន្ធ ឬផ្នែកណាមួយរបស់ឧបករណ៍តែងតែខូចដដែលៗ ថវិកាសម្រាប់ការជួសជុលមានការកើនឡើង ហើយឧបករណ៍នោះក៏មិនអាចរក្សាបាននូវភាពទុកចិត្ត និងសុវត្ថិភាពក្នុងការប្រើប្រាស់តទៅទៀតបានដែរ ។ ស្ថានភាពបែបនេះបង្ហាញឱ្យឃើញថាអាយុកាលរបស់ឧបករណ៍ត្រូវបានបញ្ចប់ ។

ឧបករណ៍ក៏អាចប្រឈមមុខនឹងកំហូចផ្សេងៗក្រៅពីកំហូចដែលបានរៀបរាប់ខាងលើដែរ ។ វាក៏សមហេតុផលដែរក្នុងការទទួលស្គាល់ថាឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយជាឧបករណ៍ដែលហួសអាយុកាល ហើយសំខាន់ជាងនេះទៅទៀតវានឹងធ្វើដំណើរតាមខ្សែកោងរបស់អាងងូតទឹក ។ ឧទាហរណ៍ក្នុងករណីឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ យើងអាចដឹងមុនថាវានឹងធ្វើដំណើរតាមខ្សែកោង (CD) ហើយវាងាយខូចនិងបាក់បែកជាងឧបករណ៍ដែលមានអាយុកាលស្ថិតលើខ្សែកោង (BC) ។

## គ. គ្រោះថ្នាក់ដល់សុវត្ថិភាពរបស់អ្នកជំងឺ ឬអ្នកប្រើប្រាស់

### ① សុវត្ថិភាពផ្នែកអគ្គិសនី

បន្ទាប់ពីការប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យអស់រយៈពេលយូរអង្វែងមក ផ្នែកអេឡិចត្រូនិច និងសៀគ្វីអគ្គិសនីភាគច្រើនចាស់ហើយខូចខាត ។ ពិសេស ផ្នែកខ្លះនឹងត្រូវរងនូវអុកស៊ីតកម្ម និងច្រេះចាប់ ។ មុនពេលអាយុកាលរបស់ឧបករណ៍បរិក្ខារពេទ្យ

ត្រូវបានបញ្ចប់ ប្រដាប់ស្រោបខ្សែភ្លើងជាប់នឹងតួឧបករណ៍អាចនឹងខូចដែលអាចបណ្តាលឱ្យកើតមានគ្រោះថ្នាក់ជាច្រើន ដូចជាការឆក់ចរន្តអគ្គិសនីដល់អ្នកប្រើប្រាស់ឧបករណ៍ជាដើម ។ ជាការពិតណាស់ឧបករណ៍ចាស់អាចបណ្តាលឱ្យមានគ្រោះថ្នាក់ជាងឧបករណ៍ថ្មី ដូចមានរៀបរាប់ក្នុង (ចំណុច (៣) សុវត្ថិភាព ក្នុងលេខរៀង ៣: លក្ខណៈពិសេសរបស់ឧបករណ៍បរិក្ខារពេទ្យ) ។

② **គ្រោះថ្នាក់ដោយការចម្លងរោគ**

ឧបករណ៍បរិក្ខារពេទ្យច្រើនតែមានមេរោគ បាក់តេរី និងវីរុស ជាពិសេសឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយនៅតាមមជ្ឈមណ្ឌលធ្វើរោគវិនិច្ឆ័យ និងព្យាបាលវេជ្ជសាស្ត្រនានា (មន្ទីរពិសោធន៍ជីវសាស្ត្រ បន្ទប់វះកាត់ជាដើម) ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដោយសារការឆ្លងរោគធ្ងន់ធ្ងរដល់បុគ្គលិកវេជ្ជសាស្ត្រ និងអ្នកជំងឺ ។

**ឃ. បញ្ហាក្នុងការដឹកជញ្ជូនឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ**

បន្ទាប់ពីមានការយល់ព្រមរវាងភាគីផ្តល់ជំនួយ និងភាគីទទួលជំនួយក្នុងការផ្តល់ឧបករណ៍បរិក្ខារពេទ្យមក ឧបករណ៍នោះត្រូវបានដឹកជញ្ជូនទៅកាន់ទីកន្លែងទទួលជំនួយ ។ ដោយសារការដឹកជញ្ជូន និងការដំឡើងសាជាថ្មី ឧបករណ៍បរិក្ខារពេទ្យនោះអាចខូច ឬបាក់បែក ហើយផ្នែកខ្លះអាចនឹងបាត់បង់ផងដែរក្នុងដំណាក់កាលទាំងបីខាងក្រោម:

១. ការរុះរើ

២. ការដឹកជញ្ជូន

៣. ការដំឡើងឡើងវិញ

**ង) បញ្ហាក្នុងពេលដំឡើង និងការផ្គុំឧបករណ៍សាជាថ្មី**

ចំពោះឧបករណ៍បរិក្ខារពេទ្យពិសេស ឬធំៗ ដូចជា CT ស្កេន ម៉ាស៊ីនថតឆ្លុះកាំរស្មីអ៊ិច ម៉ាស៊ីនវិភាគគីមីសាស្ត្រដោយស្វ័យប្រវត្តិ វាជាចាំបាច់ត្រូវការវិធីសាស្ត្រ ឬនីតិវិធីពិសេសដើម្បីដំឡើង ឬផ្គុំវា ។ ក្នុងករណីនេះ មានតែអ្នកឯកទេសតែមួយគត់ដែលអាចដំឡើងឧបករណ៍បរិក្ខារពេទ្យនោះបានសមស្រប ។ ដូច្នេះ ចាំបាច់ត្រូវមានអ្នកឯកទេសដែលមានចំណេះដឹងក្នុងការដំឡើង និងធ្លាប់បានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសទាក់ទងនឹងឧបករណ៍ទាំងនោះ ។ ជួនកាលយើងក៏ត្រូវការគ្រឿងបន្លាស់ និងសំភារៈមួយចំនួនក្នុងពេលដំឡើងឧបករណ៍ផងដែរ ។

## V. លក្ខខណ្ឌដំបូងនៅពេលទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ

ដោយសារមានមន្ទីរពេទ្យខ្លះធ្លាប់ជួបបញ្ហាមួយចំនួនក្រោយពីបានទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ដូចជាម៉ូដែលហួសសម័កាល ខ្វះគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ និងឯកសារចាំបាច់មួយចំនួន (បញ្ជាក់ជាក់ស្តែងសូមអានឧបសម្ព័ន្ធ-១) ក្រសួងសុខាភិបាលបានបង្កើតល័ក្ខខ័ណ្ឌដំបូងដែលជាតួនាទី និងការទទួលខុសត្រូវរបស់ភាគីផ្តល់ជំនួយ និងភាគីទទួលជំនួយដូចខាងក្រោម :

### ១. ការទទួលខុសត្រូវរបស់ភាគីទទួលជំនួយ

នៅពេលដែលអ្នកទទួលជំនួយសម្រេចចិត្តទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយពីអង្គភាពផ្តល់ជំនួយ អ្នកទទួលជំនួយត្រូវអនុវត្តតាមចំណុចចាំបាច់មួយចំនួនដើម្បីឱ្យឧបករណ៍អាចប្រើប្រាស់បានសមស្រប និងប្រកបដោយប្រសិទ្ធភាព។ ចំណុចទាំងនោះមានដូចជាៈ

#### ក. វិភាគពីតម្រូវការរបស់ឧបករណ៍

បន្ទាប់ពីបានទទួលព័ត៌មានពីការផ្តល់ជំនួយឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ជាដំបូងមន្ទីរពេទ្យត្រូវបញ្ជាក់ពីប្រភេទឧបករណ៍ដែលអ្នកផ្តល់ជំនួយចង់ផ្តល់ឱ្យមន្ទីរពេទ្យ។ បន្ទាប់មកទៀតប្រធានមន្ទីរពេទ្យ បុគ្គលិកផ្នែកគ្រប់គ្រង និងផ្នែកគ្លីនិកត្រូវពិចារណា និងកំណត់ថាតើឧបករណ៍នោះចាំបាច់សម្រាប់មន្ទីរពេទ្យដែរឬទេ។

#### ខ. ទំនាក់ទំនងក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុក (នៅកម្ពុជា)

បន្ទាប់ពីបានទទួលព័ត៌មានជាមូលដ្ឋានរបស់ឧបករណ៍ដែលត្រូវទទួល (ប្រភេទនៃឧបករណ៍ រោងចក្រផលិត ម៉ូដែល លេខសេរី ថ្ងៃខែឆ្នាំផលិត) ពីភាគីផ្តល់ជំនួយ មន្ទីរពេទ្យត្រូវបញ្ជាក់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុកថាតើគ្រឿងបន្ទាប់បន្សំ គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ និងគ្រឿងបន្លាស់ឧបករណ៍នោះ អាចផ្គត់ផ្គង់បានដែរឬទេ នៅពេលបច្ចុប្បន្ន និងពេលអនាគត។

### ២. ការទទួលខុសត្រូវរបស់ភាគីផ្តល់ជំនួយ

នៅពេលអ្នកផ្តល់ជំនួយសម្រេចចិត្តផ្តល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយដល់មន្ទីរពេទ្យ ភាគីផ្តល់ជំនួយត្រូវអនុវត្តតាមចំណុចចាំបាច់មួយចំនួនដូចខាងក្រោម ដើម្បីឱ្យការប្រើប្រាស់ឧបករណ៍បានសមស្របនិងប្រកបដោយប្រសិទ្ធភាព :

#### ក. ផ្តល់ព័ត៌មានជាមូលដ្ឋានទាក់ទងនឹងឧបករណ៍បរិក្ខារពេទ្យ

ព័ត៌មានទាំងនោះរួមមាន :

- ប្រភេទឧបករណ៍
- រោងចក្រផលិត

- ម៉ូដែល
- លេខស៊េរី
- ថ្ងៃ ខែ ឆ្នាំផលិត

**ខ. បញ្ជាក់ពីស្ថានភាពឧបករណ៍មុនពេលផ្តល់ជូន (ដំណើរការ ឬមិនដំណើរការ)**

ភាគីផ្តល់ជំនួយត្រូវត្រួតពិនិត្យស្ថានភាពដំណើការរបស់ឧបករណ៍បរិក្ខារពេទ្យថាតើវាមានស្ថានភាពដំណើរការល្អដែរឬទេ មុនពេលផ្តល់ឱ្យភាគីទទួលជំនួយ ។ លើសពីនេះ គួរតែរៀបចំឯកសារមួយចំនួនសម្រាប់ប្រគល់ជូនភាគីទទួលជំនួយដូចជារបាយការណ៍ស្តីពីការធ្វើតេស្តដំណើរការជាដើម ។

**គ. ភ្ជាប់មកជាមួយនូវគ្រឿងបន្ទាប់បន្សំ ផ្នែកផ្សេងៗ និងគ្រឿងប្រើប្រាស់ប្រចាំថ្ងៃដែលចាំបាច់**

ភាគីផ្តល់ជំនួយគួរតែពិនិត្យ និងបញ្ជាក់ឱ្យបានច្បាស់លាស់ថាតើឧបករណ៍បរិក្ខារពេទ្យដែលផ្តល់ជូននោះមានភ្ជាប់មកជាមួយនូវគ្រឿងបន្ទាប់បន្សំ ផ្នែកផ្សេងៗ និង គ្រឿងប្រើប្រាស់ប្រចាំថ្ងៃចាំបាច់សម្រាប់ដំណើរការឧបករណ៍បានសមស្របដែរឬទេ យ៉ាងហោចណាស់ឧបករណ៍នោះគួតែអាចដំណើរការបានក្នុងដំណាក់កាលដំបូងដែរ ។

ភាគីផ្តល់ជំនួយត្រូវភ្ជាប់មកជាមួយឧបករណ៍នូវសំភារៈទាំងនោះឱ្យបានគ្រប់ចំនួនដូចដែលមានរៀបរាប់ក្នុងឯកសារណែនាំអំពីរបៀបប្រើប្រាស់ ។

**ឃ. ឯកសារបច្ចេកទេស**

ភាគីផ្តល់ជំនួយគួរតែពិនិត្យ និង បញ្ជាក់ឱ្យបានច្បាស់ថាតើឯកសារបច្ចេកទេសត្រូវបានភ្ជាប់ជាមួយឧបករណ៍ហើយឬនៅ ។ ឯកសារបច្ចេកទេសទាំងនោះមានដូចជា ឯកសារណែនាំអំពីរបៀបប្រើប្រាស់ របៀបថែទាំជួសជុល បញ្ជីឈ្មោះគ្រឿងបន្លាស់ និងឯកសារផ្សេងៗទៀតដែលចាំបាច់ ។ យ៉ាងហោចណាស់ក៏ត្រូវមានឯកសារណែនាំអំពីរបៀបប្រើប្រាស់ឧបករណ៍ដែរព្រោះវាជាឯកសារសំខាន់ដើម្បីឱ្យការប្រើប្រាស់បានសមស្រប ។

**ង. រយៈពេលប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យ**

ភាគីផ្តល់ជំនួយគួរតែផ្តល់ព័ត៌មានទាក់ទងនឹងរយៈពេលប្រើប្រាស់ឧបករណ៍កន្លងមក ។ ក្រសួងសុខាភិបាលសូមបញ្ជាក់ថាក្រសួងនឹងមិនទទួលយកឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយជាង ៦ឆ្នាំ គិតចាប់ពីពេលផលិតឧបករណ៍ (សូមបញ្ជាក់ថា អាយុកាលរបស់ឧបករណ៍ទាំងនោះមានប្រហែល ៦ឆ្នាំ បើតាមការកំណត់ទូទាំងសកលលោក និងបទដ្ឋានអន្តរជាតិដែលគាំទ្រការកំណត់នេះ) ។

ជាមួយគ្នានេះដែរ ក្រសួងសុខាភិបាលបានកំណត់អាយុកាលឧបករណ៍បរិក្ខារពេទ្យតិចជាង ១២ឆ្នាំ ក្នុងដំណើរការសុំជម្រះបញ្ជី ។ រាល់ឧបករណ៍បរិក្ខារពេទ្យគ្រប់ប្រភេទដែលមានអាយុ ១២ឆ្នាំ ចាប់តាំងពីពេលផលិតឧបករណ៍ទាំងនោះ នឹងត្រូវសុំជម្រះបញ្ជីតាមសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ( យោងតាម "សេចក្តីណែនាំស្តីពីការសុំជម្រះបញ្ជីឧបករណ៍បរិក្ខារពេទ្យតាមលក្ខណៈបច្ចេកទេស ") ។

**ច. ស្ថានភាពបរិស្ថានពេលប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យ**

ភាគីផ្តល់ជំនួយគួរតែផ្តល់ព័ត៌មាន ថាតើឧបករណ៍ជំនួយនោះអាចដំឡើងប្រើប្រាស់ក្នុងប្រទេសកម្ពុជាបានដែរឬទេ? នៅចុងបញ្ចប់ភាគីផ្តល់ជំនួយត្រូវប្រាប់អំពីស្ថានភាពទីកន្លែងដែលប្រើឧបករណ៍នោះពីមុន ។

**ឆ. ការបណ្តុះបណ្តាលអ្នកប្រើប្រាស់**

ប្រសិនបើមន្ទីរពេទ្យទទួលជំនួយឧបករណ៍ដែលទំនើប ឬសាំញ៉ាំ ត្រូវតែមានការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់អំពីរបៀបប្រើប្រាស់ និងរបៀបលើកដាក់ឧបករណ៍បរិក្ខារពេទ្យ ។ មន្ទីរពេទ្យត្រូវតែជូនដំណឹងដល់ម្ចាស់ជំនួយប្រសិនបើមន្ទីរពេទ្យត្រូវការបណ្តុះបណ្តាលអ្នកប្រើប្រាស់ឧបករណ៍ ។

**៣. ការព្រមព្រៀងគ្នាទៅវិញទៅមក ( ភាគីផ្តល់ជំនួយ និងភាគីទទួលជំនួយ)**

នៅពេលភាគីផ្តល់ជំនួយផ្តល់ឧបករណ៍បរិក្ខារពេទ្យដល់ភាគីទទួលជំនួយ ភាគីទាំងពីរគួរតែមានការយល់ព្រមគ្នាទៅវិញទៅមកនូវចំណុចមួយចំនួនដូចខាងក្រោមដើម្បីចៀសវាងបញ្ហា ឬឧបសគ្គដែលអាចកើតមានឡើងរវាងភាគីទាំងពីរ ។ ក្រសួងសុខាភិបាលគួរតែរៀបចំឯកសារព្រមព្រៀងគ្នាមួយចំនួនដូចជាអនុស្សរណៈនៃការយល់ព្រមគ្នា ដោយផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

**១. ការទទួលខុសត្រូវលើចំណាយដំបូងនៅពេលប្រគល់ឧបករណ៍បរិក្ខារពេទ្យ**

នៅពេលអ្នកផ្តល់ជំនួយផ្តល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយដល់មន្ទីរពេទ្យ គាត់គួរតែផ្តល់ជូនផងដែរនូវចំណាយដំបូងដែលចាំបាច់ក្នុងការទទួលឧបករណ៍ដូចជាៈ

( ក ) ថ្លៃធ្វើដំណើរ

( ខ ) ថ្លៃដំឡើង

( គ ) ថ្លៃថែទាំ និង

( ឃ ) ចំណាយផ្សេងៗទៀតដែលចាំបាច់

ចំណុចទាំងអស់ខាងលើនេះគួរតែបញ្ជាក់ឱ្យបានច្បាស់លាស់ថាតើភាគីមួយណាជាអ្នក

ទទួលខុសត្រូវលើចំណាយទាំងនេះ ។

**២. គណៈកម្មាធិការរៀបចំអនុស្សរណៈនៃការយល់ព្រមគ្នា**

ក្រសួងសុខាភិបាលគួររៀបចំអនុស្សរណៈនៃការយល់ព្រមគ្នារវាងភាគីផ្តល់ជំនួយ និងភាគីទទួលជំនួយ ( មន្ទីរពេទ្យ) ដើម្បីបញ្ជាក់ពីលទ្ធភាព និងការទទួលខុសត្រូវរបស់ភាគីម្នាក់ៗ និងដើម្បីជៀសវាងបញ្ហាដែលអាចកើតមានឡើងបន្ទាប់ពីការប្រគល់ឧបករណ៍បរិក្ខារពេទ្យ ។

**ក.ព្រំដែននៃការប្រគល់ឧបករណ៍បរិក្ខារពេទ្យៈ និយមន័យ**

ដើម្បីជៀសបញ្ហា ឬឧបសគ្គផ្សេងៗ ដូចដែលមានចែងនៅក្នុងលេខរៀង ៦ ខាងលើ "**លក្ខខណ្ឌដំបូងក្នុងការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ**" ក្រសួងសុខាភិបាលបានរៀបចំនិយមន័យនៃការប្រគល់ឧបករណ៍បរិក្ខារពេទ្យនេះផងដែរ ។

ភាគីផ្តល់ជំនួយមានតួនាទីទទួលខុសត្រូវក្នុងការប្រគល់ឧបករណ៍បរិក្ខារពេទ្យ ចាប់តាំងពីពេលប្រគល់រហូតដល់ឧបករណ៍នោះត្រូវបានរៀបចំរួចរាល់ហើយអាចប្រើប្រាស់បានដោយភាគីទទួលជំនួយ ។ ព្រំដែននៃការប្រគល់មានបង្ហាញដូចខាងក្រោមៈ




មន្ទីរពេទ្យត្រូវត្រួតពិនិត្យ និងបញ្ជាក់អំពីចំណុចសំខាន់ៗទាំងអស់ដែលមាននៅក្នុងបញ្ជីត្រួតពិនិត្យ (ឧបសម្ព័ន្ធ-២) ហើយចុះបញ្ជីឧបករណ៍ទាំងនោះក្នុងបញ្ជីសារពើភ័ណ្ឌឱ្យបានត្រឹមត្រូវ ។

**ខ. ការផ្ទេរកម្មសិទ្ធិ**

បន្ទាប់ពីការប្រគល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយពីភាគីផ្តល់ជំនួយដល់ភាគីទទួលជំនួយមក ភាគីទាំងពីរគួរតែមានការសម្រេចចិត្តថាតើអ្នកណាជាម្ចាស់

កម្មសិទ្ធិឧបករណ៍បរិក្ខារពេទ្យនោះ (ភាពជាកម្មសិទ្ធិ) ។ ភាគីទាំងពីរគួរតែធ្វើការពិភាក្សា និងសម្រេចឱ្យបានច្បាស់លាស់ពីបញ្ហាកម្មសិទ្ធិនេះ ហើយសរសេរចូលក្នុងអនុស្សរណៈនៃការយល់ព្រមគ្នា។

**គ. ការទទួលខុសត្រូវលើការគ្រប់គ្រងថែទាំ**

បន្ទាប់ពីការប្រគល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ភាគីទាំងពីរគួរតែមានការបញ្ជាក់ឱ្យបានច្បាស់លាស់ថាតើនរណាជាអ្នកទទួលខុសត្រូវលើការគ្រប់គ្រងថែទាំដែលរួមទាំងចំណាយផងដែរ។

**ឃ. សិទ្ធិនៃការសុំជម្រះបញ្ជី**

នៅពេលភាគីផ្តល់ជំនួយប្រគល់ឧបករណ៍បរិក្ខារពេទ្យដល់ភាគីទទួលជំនួយរួចមក ភាគីទាំងពីរគួរតែកំណត់ថាតើនរណាជាអ្នកទទួលខុសត្រូវលើការសុំជម្រះបញ្ជីឧបករណ៍បរិក្ខារពេទ្យទាំងនោះ។ ភាគីទាំងពីរគួរធ្វើការពិភាក្សា និងពន្យល់ឱ្យបានច្បាស់លាស់អំពីសិទ្ធិនេះ និងកត់ត្រាក្នុងកំណត់ហេតុព្រមព្រៀងគ្នា។

**ង. ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ទទួលឧបករណ៍**

របាយការណ៍ទទួលឧបករណ៍បរិក្ខារពេទ្យត្រូវផ្ញើជូនក្រសួងសុខាភិបាល និងភ្ជាប់ជាមួយនឹងកំណត់ហេតុព្រមព្រៀងគ្នា។

**ច. ព័ត៌មានសម្រាប់ទំនាក់ទំនង**

ព័ត៌មានសម្រាប់ទំនាក់ទំនងរវាងភាគីទាំងពីរត្រូវរួមបញ្ចូលចំណុចដូចខាងក្រោម:

១. ឈ្មោះអង្គភាព

២. ឈ្មោះអ្នកទទួលបន្ទុក

៣. លេខទូរស័ព្ទ

៤. លេខទូរសារ

៥. អ៊ីមែល

៦. ព័ត៌មានផ្សេងៗ

**៣. ការផ្តល់សិទ្ធិលើស្តង់ដាផលិតផលដើម**

ជាទូទៅនៅក្នុងប្រទេសអភិវឌ្ឍ ឧបករណ៍បរិក្ខារពេទ្យត្រូវមានបិតស្លាកអនុញ្ញាតការផលិតតាមបទដ្ឋានឧស្សាហកម្មដែលផ្តល់សិទ្ធិដោយប្រទេសនោះ។

ការផ្តល់សិទ្ធិលើការផលិតតាមបទដ្ឋានឧស្សាហកម្មគឺមានន័យថាប្រទេសនីមួយៗមានបទដ្ឋានឧស្សាហកម្មរបស់ខ្លួនផ្សេងៗគ្នា ។

រាល់ផលិតផលឧបករណ៍បរិក្ខារពេទ្យត្រូវធ្វើការត្រួតពិនិត្យមុខងារ និងដំណើរការរបស់វា ព្រមទាំងធ្វើការតេស្តសាកល្បងពីសុវត្ថិភាពដោយផ្អែកតាមច្បាប់បទដ្ឋានជាផ្លូវការដែលបានបង្កើតឡើងដោយរដ្ឋាភិបាលនៃប្រទេសនីមួយៗ ។ ប្រសិនបើផលិតផលមិនបានឆ្លងកាត់ការត្រួតពិនិត្យទាំងនោះទេ វាមិនអាចបន្តការផលិត និងលក់នៅលើទីផ្សារបានដែរ ។ ផ្ទុយទៅវិញ យើងអាចនិយាយបានថានៅពេលដែលឧបករណ៍បរិក្ខារពេទ្យបានឆ្លងកាត់ការត្រួតពិនិត្យដូចខាងលើរួចហើយ ឧបករណ៍ទាំងនោះអាចទុកចិត្តបាន និងអាចប្រើប្រាស់ប្រកបដោយសុវត្ថិភាព ។

ការផ្តល់សិទ្ធិលើការផលិតតាមបទដ្ឋានឧស្សាហកម្មថ្នាក់ជាតិរបស់ប្រទេសនីមួយៗមានដូចជានៅក្នុងប្រទេសជប៉ុនមានបទដ្ឋានឧស្សាហកម្មនៃប្រទេសជប៉ុន (JIS) និងនៅសហគមន៍អឺរ៉ុបមានសញ្ញាសម្គាល់ផលិតផលរបស់សហគមន៍អឺរ៉ុប (CE) សម្រាប់កំណត់ពីលក្ខណៈបទដ្ឋាននៃផលិតផលនីមួយៗផងដែរ ។

លើសពីនេះ ទាក់ទងនឹងបញ្ហាការផ្តល់សិទ្ធិ តើគួររាប់បញ្ចូលក្នុងលក្ខខណ្ឌដំបូងដែរឬទេ ។ ភាគីទាំងពីរគួរតែធ្វើការពិភាក្សាលើបញ្ហានេះ ថាតើវាសំខាន់ដែរឬទេ ។

## VI. បន្ទាប់ពីទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ

### ១. ការចុះឈ្មោះឧបករណ៍បរិក្ខារពេទ្យក្នុងបញ្ជីសារពើភ័ណ្ឌ

បន្ទាប់ពីបានទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ខាងមន្ទីរពេទ្យ (ផ្នែករដ្ឋបាល ឬផ្នែកទទួលបន្ទុកឧបករណ៍បរិក្ខារពេទ្យ) ត្រូវតែចុះឈ្មោះឧបករណ៍បរិក្ខារពេទ្យក្នុងបញ្ជីសារពើភ័ណ្ឌឱ្យបានឆាប់បំផុត ព្រមទាំងចុះឈ្មោះឧបករណ៍បរិក្ខារពេទ្យនោះផងដែរក្នុងកម្មវិធីគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ MEDEMIS របស់គម្រោង MEDEM ក្នុងទម្រង់ ២-៤ ។

ក្នុងពេលចុះឈ្មោះ ត្រូវកត់ត្រាថ្ងៃ ខែ ឆ្នាំផលិត និងដំឡើង ក៏ដូចជាលេខ ID របស់ឧបករណ៍បរិក្ខារពេទ្យ ។

### ២. ការធ្វើរបាយការណ៍ជូនក្រសួងសុខាភិបាល

នៅពេលដែលមន្ទីរពេទ្យទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ត្រូវផ្ញើរបាយការណ៍ទទួលឧបករណ៍បរិក្ខារពេទ្យជូននាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល ។

## VII. ឯកសារយោង

### ១. ករណីសិក្សាចំពោះការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ (ឧបសម្ព័ន្ធ-១)

ក្នុងឧបសម្ព័ន្ធនេះមានរៀបរាប់ពីករណីសិក្សាជាក់ស្តែងរួមទាំងករណីល្អ និងមិនល្អដែលបានកើតឡើងនៅតាមមន្ទីរពេទ្យមួយចំនួនពេលទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ។

### ២. បញ្ជីត្រួតពិនិត្យតាមដំណាក់កាលនៃការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ (ឧបសម្ព័ន្ធ-២)

បន្ទាប់ពីបានទទួលព័ត៌មានអំពីការផ្តល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ មន្ទីរពេទ្យត្រូវប្រើបញ្ជីត្រួតពិនិត្យ "ឧបសម្ព័ន្ធ-២" ដើម្បីចាត់ថ្នាក់ឧបករណ៍បរិក្ខារពេទ្យ និងដើម្បីបញ្ជាក់ពីស្ថានភាពរបស់ឧបករណ៍។

### ៣. បញ្ជីនៃគ្រឿងបន្លាស់បន្ទាប់បន្សំ គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ និងគ្រឿងបន្លាស់សម្រាប់ឧបករណ៍បរិក្ខារពេទ្យដែលចាំបាច់ (ឧបសម្ព័ន្ធ-៣)

ក្រុមការងាររោងជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យបានរៀបចំបញ្ជីគ្រឿងបន្ទាប់បន្សំ និងគ្រឿងប្រើប្រាស់ប្រចាំថ្ងៃ នៃឧបករណ៍បរិក្ខារពេទ្យមួយចំនួនសម្រាប់ប្រើប្រាស់ជាឯកសារយោង។ ឧបករណ៍បរិក្ខារពេទ្យទាំងនេះបានជ្រើសរើសដោយប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៃក្រសួងសុខាភិបាល ហើយវាក៏មានរៀប រាប់ផងដែរក្នុងសៀវភៅមគ្គុទេសក៏សម្រាប់ការថែទាំឧបករណ៍បរិក្ខារពេទ្យ។

ក្នុងករណីទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ភាគីទទួលគួរតែបញ្ជាក់ជាមួយម្ចាស់ផ្តល់ជំនួយថាតើគាត់អាចផ្តល់គ្រឿងបន្ទាប់បន្សំ និងគ្រឿងប្រើប្រាស់ប្រចាំថ្ងៃដែលចាំបាច់ដើម្បីឱ្យការប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យប្រកបដោយប្រសិទ្ធភាពដែរឬទេ។

### ៤. បញ្ជីឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍បរិក្ខារពេទ្យក្នុងស្រុក (ឧបសម្ព័ន្ធ-៤)

នៅពេលឧបករណ៍បរិក្ខារពេទ្យមានបញ្ហា ឬខូច ចាំបាច់ត្រូវធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍បរិក្ខារពេទ្យ ដូច្នេះបញ្ជីក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍បរិក្ខារពេទ្យក្នុងស្រុកត្រូវបានភ្ជាប់មកជាមួយនឹងសេចក្តីណែនាំនេះដើម្បីឱ្យមន្ទីរពេទ្យងាយស្រួលក្នុងការទំនាក់ទំនង។

បញ្ជីឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍បរិក្ខារពេទ្យក្នុងស្រុកមានព័ត៌មានមួយចំនួនដូចជាលេខទូរស័ព្ទ អ៊ីម៉ែល និងក្រុមហ៊ុនទទួលបន្ទុកផ្គត់ផ្គង់ឧបករណ៍បរិក្ខារពេទ្យទៅតាមរោងចក្រផលិត។ អាស្រ័យហេតុនេះមន្ទីរពេទ្យនីមួយៗត្រូវបញ្ជាក់ឱ្យបានច្បាស់ជាមួយអ្នកផ្តល់ជំនួយអំពីព័ត៌មានមួយចំនួនដូចជា ម៉ូដែល រោងចក្រផលិត ហើយទាក់ទងជាមួយក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍បរិក្ខារពេទ្យក្នុងស្រុកនៅពេលចាំបាច់។

**៥. គំរូអនុស្សរណៈនៃការយោគយល់គ្នាក្នុងការប្រគល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ (ឧបសម្ព័ន្ធ-៥)**

ដើម្បីឱ្យមានលក្ខណៈស្តង់ដា មន្ទីរពេទ្យនីមួយៗគួរធ្វើអនុស្សរណៈនៃការយោគយល់គ្នារវាងភាគីទទួល និងភាគីផ្តល់ជំនួយ ដែលមានគម្រូក្នុងឧបសម្ព័ន្ធ-៥។

**៦. ព័ត៌មាននៃឧបករណ៍បរិក្ខារពេទ្យ (សម្រាប់ទទួលយកឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ)(ឧបសម្ព័ន្ធ-៦)**

ដើម្បីឱ្យមានលក្ខណៈស្តង់ដា មន្ទីរពេទ្យនីមួយៗត្រូវបំពេញទម្រង់ព័ត៌មាននៃឧបករណ៍បរិក្ខារពេទ្យដូចមានភ្ជាប់ក្នុង (ឧបសម្ព័ន្ធ-៦) ភ្លាមៗនៅពេលទទួលបានឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយពីអង្គភាពផ្តល់ជំនួយ រួចថតចម្លងមួយច្បាប់ផ្ញើជូនក្រសួងសុខាភិបាល។

## ឧបសម្ព័ន្ធ-១៖ ករណីសិក្សាចំពោះការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ

ក្នុងឧបសម្ព័ន្ធនេះយើងនឹងបង្ហាញអំពីករណីសិក្សាជាក់ស្តែង ដែលបានកើតឡើងនៅតាមមន្ទីរពេទ្យមួយចំនួន ទាក់ទងនឹងការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ។ ខាងក្រោមនេះមានរៀបរាប់ទាំង ករណីល្អ និង មិនល្អរបស់ស្ថានភាពដំណើរការ និងស្ថានភាពប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ ។

### ១. ករណីល្អ

| **ក. ឧបករណ៍អាចប្រើប្រាស់បានយ៉ាងល្អដោយមានការគាំទ្រផ្នែកបច្ចេកទេសពីជំនាញការ** |
|---|
| **មន្ទីរពេទ្យបង្អែក « ក »** ÷<br><br>នៅក្នុងឆ្នាំ២០០៣ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានផ្តល់ឧបករណ៍ផ្នែកមន្ទីរពិសោធន៍ដល់ មន្ទីរពេទ្យនេះ ( ទូរក្សាកំដៅបើក្នុងមន្ទីរពិសោធន៍ ម៉ាស៊ីនញ៉េកសូលុយស្យុង និងឧបករណ៍វិភាគប្រើបាច់ ពន្លឺ) ។ ផ្ទុយទៅវិញម៉ាស៊ីនទាំងនេះមិនបានប្រើប្រាស់ ហើយទុកចោលក្នុងបន្ទប់មន្ទីរពិសោធន៍ ។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ២០០៧ មកមានអ្នកស្ម័គ្រចិត្តមួយចំនួនដែលជាអ្នកបច្ចេកទេសមន្ទីរពិសោធន៍បានណែនាំ មន្ទីរពេទ្យពីរបៀបប្រើប្រាស់ឧបករណ៍ទាំងនេះ ។ ក្រោយមកឧបករណ៍ទាំងនេះអាចប្រើប្រាស់បានយ៉ាងល្អ ។ |

| **ខ. អង្គភាពផ្តល់ជំនួយទទួលខុសត្រូវលើចំណាយសម្រាប់ការថែទាំ** |
|---|
| **មន្ទីរពេទ្យបង្អែក « ខ »** ÷<br>អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពវេជ្ជសាស្ត្របានផ្តល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយដល់ បន្ទប់វះកាត់នៃមន្ទីរពេទ្យនេះដើម្បីផ្ទេរចំណេះដឹងផ្នែកបច្ចេកទេសចក្ខុរោគ ។<br>ក្នុងអំឡុងពេលគម្រោង អង្គការក្រៅរដ្ឋាភិបាលនេះជួយឧបត្ថម្ភចំណាយលើការថែទាំឧបករណ៍តាមរយៈ មូលនិធិក្នុងស្រុក ។ |

| **គ. វិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យថ្មីបានណែនាំដល់មន្ទីរពេទ្យតាមរយៈការផ្តល់ឧបករណ៍បរិក្ខារពេទ្យ ដែលគេប្រើហើយ** |
|---|
| **មន្ទីរពេទ្យបង្អែក « គ »** ÷<br>ក្រុមហ៊ុនឯកជនបានដំឡើងម៉ាស៊ីន CT ស្កេនដែលគេប្រើហើយនៅក្នុងមន្ទីរពេទ្យនេះ ។ មន្ទីរពេទ្យ និង ក្រុមហ៊ុនបានសម្រេចធ្វើកិច្ចសន្យារយៈពេល ៥ឆ្នាំ ក្នុងការប្រើប្រាស់ម៉ាស៊ីន ។ ក្នុងអំឡុងពេលប្រើប្រាស់ ក្រុមហ៊ុនបានឧបត្ថម្ភការថែទាំតាមតម្រូវការរបស់ម៉ាស៊ីននេះ ។ ដើម្បីគ្រប់គ្រងថ្លៃចំណាយនេះបាន ភាគរយ នៃប្រាក់ហិរញ្ញប្បទានត្រូវបានកាត់ទុកដើម្បីចំណាយជូនក្រុមហ៊ុន ។ ពេលចប់កុងត្រាឧបករណ៍នោះក្លាយជា |

កម្មសិទ្ធិរបស់មន្ទីរពេទ្យ ។

នេះជាលើកដំបូងហើយដែលម៉ាស៊ីន CT ស្កេននេះមានប្រើប្រាស់នៅក្នុងមន្ទីរពេទ្យ ។

ជាលទ្ធផលវិធីសាស្ត្រក្នុងការធ្វើរោគវិនិច្ឆ័យត្រូវបានពង្រីក ហើយគុណភាពក៏មានការរីកចម្រើនឡើង ។

## ២. ករណីមិនល្អ

**ក. បុគ្គលិកផ្នែកវេជ្ជសាស្ត្រជាទូទៅមិនចូលចិត្តប្រើឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយទេ ព្រោះម៉ូដែលរបស់វាហួសសម័យកាល ដែលមិនអាចប្រើប្រាស់បានតាមបំណងប្រាថ្នា**

**មន្ទីរពេទ្យបង្អែក « ឃ »** ÷

អង្គការមិនមែនរដ្ឋាភិបាលផ្នែកវេជ្ជសាស្ត្របានបញ្ជូនឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ និងគ្រឿងប្រើប្រាស់ប្រចាំថ្ងៃក្នុងផ្នែកវេជ្ជសាស្ត្រ ( បំពង់កាទេទែ បំពង់បឺតស្លេស្ម សឺរ៉ាំងចាក់ថ្នាំជាដើម) ពីរឡានកុងទីន័រ មកឱ្យប្រទេសកម្ពុជា ។ ប៉ុន្តែឧបករណ៍បរិក្ខារពេទ្យទាំងអស់នោះបានផលិតតាំងពី ២០ឆ្នាំមុន ហើយម៉ូដែល របស់វាហួសសម័យកាលដែលធ្វើឱ្យអ្នកប្រើប្រាស់មិនចង់ប្រើប្រាស់វា ។ ដោយហេតុនេះហើយឧបករណ៍ទាំង នោះត្រូវបានទុកចោលក្នុងឃ្លាំង ។

នេះជាករណីមិនល្អមួយ ព្រោះឧបករណ៍ទាំងនោះគួរតែបោះចោលនៅកន្លែងដែលសមស្របក្នុងប្រទេសដែលប្រើប្រាស់ឧបករណ៍នោះ ។ នាពេលបច្ចុប្បន្នប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍ ដូច្នេះមិនគួរឱ្យមានបញ្ហានេះកើតឡើងទៀតទេ ។

**បទពិសោធន៍:**

ប្រសិនបើភាគីផ្តល់ជំនួយប្រាប់ដល់មន្ទីរពេទ្យជាមុនអំពីព័ត៌មានជាមូលដ្ឋានខ្លះៗដូចជា ប្រភេទឧបករណ៍ ម៉ូដែល ថ្ងៃខែឆ្នាំផលិត រយៈពេលប្រើប្រាស់ និងស្ថានភាពរបស់វានៅពេលធ្វើផែនការផ្តល់ជំនួយ មន្ទីរពេទ្យអាចធ្វើការពិចារណា និងសម្រេចចិត្តថាតើមន្ទីរពេទ្យត្រូវការឧបករណ៍ទាំងនោះដែរឬទេ ។

**ខ. ឧបករណ៍បរិក្ខារពេទ្យទទួលមកក្នុងស្ថានភាពខូច ហើយមិនអាចប្រើប្រាស់បានតាំងពីថ្ងៃទទួល**

**មន្ទីរពេទ្យបង្អែក « ង »** ÷

អង្គការសាសនាមួយបានផ្តល់ឧបករណ៍វាស់មេរោគដល់មន្ទីរពេទ្យនេះ ។ ចាប់តាំងពីពេលទទួលឧបករណ៍នោះមិនអាចដំណើរការបាន ។

**មន្ទីរពេទ្យបង្អែក « ច »** ÷

អង្គការមិនមែនរដ្ឋាភិបាលមួយបានផ្តល់ម៉ាស៊ីនបូមស្លេស្មដល់មន្ទីរពេទ្យនេះ ។ ជាអកុសលឧបករណ៍នោះមានឮសំឡេងជាប់ ខូចអេក្រង់ ហើយពេលមកដល់ភ្លាមមានបាក់ផ្នែកខ្លះនៅលើបន្ទះប្រតិបត្តិការ ។

**បទពិសោធន៍:**

អ្នកផ្តល់ជំនួយគួរតែទទួលខុសត្រូវក្នុងការប្រគល់ឧបករណ៍បរិក្ខារពេទ្យ ដែលរួមមានការដំឡើង ព្រមទាំងការធ្វើតេស្តដំណើរការដំបូងដើម្បីឱ្យប្រាកដថាវាអាចដំណើរការល្អនៅក្នុងមន្ទីរពេទ្យ ។

**គ. ឧបករណ៍បរិក្ខារពេទ្យដែលបានទទួលពីអ្នកផ្តល់ជំនួយមិនមានគ្រឿងប្រើប្រាស់ប្រចាំថ្ងៃ និងគ្រឿងបន្លាស់ចាំបាច់មួយចំនួន**

**មន្ទីរពេទ្យជាតិ « ឆ »** ៖

អង្គការមិនមែនរដ្ឋាភិបាលមួយបានផ្តល់ម៉ាស៊ីនវិភាគគីមីសាស្ត្រដោយស្វ័យប្រវត្តិដល់មន្ទីរពេទ្យ ។ ម៉ាស៊ីននោះ មិនអាចប្រើប្រាស់បានដោយសារកម្មវិធីដែលត្រូវបញ្ចូលដើម្បីដំណើរការម៉ាស៊ីនដំបូងមិនមានភ្ជាប់មកជាមួយម៉ាស៊ីននោះ ។ ក្រោយមកប្រធានផ្នែកមន្ទីរពិសោធន៍នៃមន្ទីរពេទ្យនេះបានទាក់ទងទៅអង្គការនោះ ប៉ុន្តែពិតជាគួរឱ្យភ្ញាក់ផ្អើលណាស់ព្រោះសូម្បីតែអង្គការនោះក៏គ្មានកម្មវិធីនោះដែរ ។ ជាលទ្ធផលម៉ាស៊ីនមិនអាចប្រើប្រាស់បាន ។

**បទពិសោធន៍:**

មុនពេលដឹកជញ្ជូនអ្នកផ្តល់ជំនួយគួរតែភ្ជាប់មកជាមួយនូវផ្នែកចាំបាច់ទាំងអស់រួមទាំងកម្មវិធីសម្រាប់ដំណើរការម៉ាស៊ីនផងដែរ ។ លើសពីនេះភាគីទទួលជំនួយត្រូវស្នើសុំ និងបញ្ជាក់ពីខ្លឹមសារនៅក្នុងវិក័យប័ត្រឱ្យបានច្បាស់លាស់មុនពេលបញ្ជូនឧបករណ៍បរិក្ខារពេទ្យមក ។

**ឃ. ឯកសារណែនាំអំពីរបៀបប្រើប្រាស់មិនមានភ្ជាប់មកជាមួយឧបករណ៍បរិក្ខារពេទ្យ**

**មន្ទីរពេទ្យបង្អែក « ជ »** ៖

អង្គការមិនមែនរដ្ឋាភិបាលមួយបានផ្តល់ឧបករណ៍សម្រួលដង្ហើមចំនួន ៣ គ្រឿងដែលមានម៉ូដែលដូចគ្នាដល់មន្ទីរពេទ្យនេះ ។ ប៉ុន្តែគ្មានឯកសារណែនាំអំពីរបៀបប្រើប្រាស់ និងគ្រឿងបន្ទាប់បន្សំចាំបាច់ទេ ។ ដូចនេះហើយ បុគ្គលិកវេជ្ជសាស្ត្រនៅមន្ទីរពេទ្យមិនដឹងពីរបៀបប្រើប្រាស់ឧបករណ៍នោះ ។

**បទពិសោធន៍:**

ម្ចាស់ជំនួយគួរតែបញ្ចូលឯកសារបច្ចេកទេស (ឯកសារណែនាំអំពីរបៀបប្រើប្រាស់ ឯកសារណែនាំអំពីរបៀបថែទាំជួសជុល ឬបញ្ជីគ្រឿងបន្លាស់ជាដើម) ដើម្បីឱ្យការប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យបានសមស្រប ។

ម្យ៉ាងទៀត ភាគីទទួលជំនួយត្រូវបញ្ជាក់ជាមួយភាគីផ្តល់ជំនួយថាតើមានយកឯកសារណែនាំទាំងនោះភ្ជាប់មកជាមួយដែរឬទេមុនពេលទទួលឧបករណ៍ ។

| |
|---|
| **ង. គ្មានសេវាថែទាំជួសជុល ឬគ្រឿងបន្លាស់ និង គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ ដោយសារគ្មានក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុក** |
| **មន្ទីរពេទ្យបង្អែក « ឈ »** ÷<br>អង្គការសាសនាមួយបានផ្តល់ ទូរក្សាកំដៅប្រើក្នុងមន្ទីរពិសោធន៍ និងម៉ាស៊ីនញែកសូលុយស្យុងដល់មន្ទីរពេទ្យនេះ ។ ផ្នែកមន្ទីរពិសោធន៍បានប្រើប្រាស់វាអស់រយៈពេលជាង ១ ឆ្នាំ បន្ទាប់មកម៉ាស៊ីនទាំងនោះខូច ។ មន្ទីរពេទ្យបានទាក់ទងក្រុមហ៊ុនក្នុងស្រុកដែលលក់ឧបករណ៍ស្រដៀងគ្នានេះជាច្រើនកន្លែង ប៉ុន្តែដោយសារតែឧបករណ៍នេះគ្មានបញ្ជាក់ពីឈ្មោះរោងចក្រ និងប្រទេសផលិត ក្រុមហ៊ុនក្នុងស្រុកមិនអាចទាក់ទងជាមួយរោងចក្រផលិតដើម្បីទិញគ្រឿងបន្លាស់ឧបករណ៍នេះបាន ។<br>**បទពិសោធន៍:**<br>មន្ទីរពេទ្យដែលជាអ្នកទទួលជំនួយគួរតែបញ្ជាក់ជាមួយក្រុមហ៊ុនក្នុងស្រុកជាមុនសិនមុនពេលទទួលយកឧបកណ៍បរិក្ខារពេទ្យទាំងនោះថាតើមានក្រុមហ៊ុនអាចផ្គត់ផ្គង់គ្រឿងបន្ទាប់បន្សំ និង គ្រឿងបន្លាស់ ព្រមទាំងសេវាថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យទាំងនោះបានដែរឬទេ ។ |

| |
|---|
| **ច.មន្ទីរពេទ្យព្យាយាមទាក់ទងអង្គភាពផ្តល់ជំនួយដោយផ្ទាល់នៅពេលឧបករណ៍បរិក្ខារពេទ្យខូច ប៉ុន្តែមិនអាចទាក់ទងបាន** |
| **មន្ទីរពេទ្យបង្អែក « ញ »** ÷<br>សាកលវិទ្យាល័យវេជ្ជសាស្ត្រមួយបានផ្តល់ម៉ាស៊ីនវិភាគអេឡិចត្រូលីតដល់មន្ទីរពេទ្យ ។ ១ ឆ្នាំក្រោយមកម៉ាស៊ីននេះខូច ។ ប្រធានផ្នែកមន្ទីរពិសោធន៍បានព្យាយាមទាក់ទងជាមួយសាកលវិទ្យាល័យនោះ ប៉ុន្តែពុំបានសម្រេច ។ ជាលទ្ធផល ម៉ាស៊ីននោះត្រូវបានទុកចោល ។<br>**បទពិសោធន៍:**<br>គួរតែមានអនុស្សរណៈនៃការយោគយល់គ្នារវាងភាគីផ្តល់ជំនួយនិងភាគីទទួលជំនួយ ជាពិសេសត្រូវរៀបរាប់ឱ្យបានច្បាស់តើនណាជាអ្នកទទួលខុសត្រូវក្នុងការថែទាំឧបករណ៍នេះបន្ទាប់ពីការប្រគល់ឧបករណ៍ ។ |

# ឧបសម្ព័ន្ធ-២: បញ្ជីត្រួតពិនិត្យតាមដំណាក់កាលនៃការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ

| ល.រ | ចំណុចត្រួតពិនិត្យ | នីតិវិធីនៃការបញ្ជាក់បន្ថែម | លទ្ធផលត្រួតពិនិត្យ |
|---|---|---|---|
| I. | **ការទទួលខុសត្រូវរបស់ភាគីទទួលជំនួយៈ** | នៅពេលភាគីទទួលបានសម្រេចចិត្តទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយពីភាគីផ្តល់ជំនួយ ភាគីទទួលត្រូវដោះស្រាយបញ្ហាមួយចំនួនដូចខាងក្រោមដើម្បីឱ្យឧបករណ៍អាចប្រើប្រាស់បានសមស្រប និងប្រកបដោយប្រសិទ្ធភាព។ | សម្គាល់ |
| | **ក. វិភាគពីតម្រូវការរបស់ឧបករណ៍**<br>១. ជំហានដំបូងៈ ធ្វើការបញ្ជាក់ជាមួយភាគីផ្តល់ជំនួយអំពីប្រភេទនៃឧបករណ៍បរិក្ខារពេទ្យដែលនឹងត្រូវផ្តល់ជូនមន្ទីរពេទ្យ។<br>២. មន្ទីរពេទ្យទទួលជំនួយត្រូវធ្វើការពិចារណាតើគួរទទួលយកឧបករណ៍បរិក្ខារពេទ្យជំនួយនោះដែរឬទេ? | ១) បញ្ជាក់ជាមួយម្ចាស់ជំនួយអំពីប្រភេទឧបករណ៍បរិក្ខារពេទ្យដែលនឹងត្រូវផ្តល់ជំនួយ។<br>២) ប្រធានមន្ទីរពេទ្យ ព្រមទាំងនាយផ្នែកសំខាន់ៗនៅក្រោមឱវាទត្រូវធ្វើការពិចារណានិងកំណត់ថាគួរតែទទួលឬអត់។ | ធ្វើការសម្រេចចិត្តទទួល<br>ឬមិនទទួលឧបករណ៍បរិក្ខារពេទ្យ<br>បាទ/ចាស ឬ ទេ |
| | **ខ. ទំនាក់ទំនងក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុក (នៅកម្ពុជា)**<br>ទាក់ទងជាមួយភ្នាក់ងារក្នុងស្រុកអំពីលទ្ធភាពបន្តផ្គត់ផ្គង់នូវគ្រឿងបន្លាស់ គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ និងគ្រឿងបន្ទាប់បន្សំ។ | បញ្ជាក់ជាមួយភ្នាក់ងារក្នុងស្រុកថាតើពួកគាត់មានលទ្ធភាពបន្តផ្គត់ផ្គង់គ្រឿងបន្លាស់ គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ គ្រឿងបន្ទាប់បន្សំ និងសេវាកម្មជួសជុលដល់ឧបករណ៍បរិក្ខារពេទ្យនោះដែរឬទេនាពេលបច្ចុប្បន្ន និងអនាគត។ | លទ្ធភាពបន្តផ្គត់ផ្គង់របស់ភ្នាក់ងារក្នុងស្រុក<br>បាទ/ចាស ឬ ទេ |

| II. | **ការទទួលខុសត្រូវរបស់ភាគីផ្តល់ជំនួយ:** | នៅពេលភាគីផ្តល់ជំនួយសម្រេចផ្តល់ជំនួយឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយដល់ភាគីទទួលជំនួយ គាត់ត្រូវដោះស្រាយបញ្ហាមួយចំនួនដូចខាងក្រោមដើម្បីឱ្យឧបករណ៍អាចប្រើប្រាស់បានសមស្រប និងប្រកបដោយប្រសិទ្ធភាព ។ | សម្គាល់ |
|---|---|---|---|
| | **១. ផ្តល់ព័ត៌មានជាមូលដ្ឋានទាក់ទងនឹងឧបករណ៍បរិក្ខារពេទ្យ**<br>ភាគីផ្តល់ជំនួយត្រូវផ្តល់ព័ត៌មានជាមូលដ្ឋានទាក់ទងនឹងឧបករណ៍បរិក្ខារពេទ្យដែលត្រូវផ្តល់ជំនួយ ។ | ភាគីផ្តល់ជំនួយត្រូវប្រាប់ពីព័ត៌មានមួយចំនួនដូចខាងក្រោមដល់មន្ទីរពេទ្យទទួលជំនួយ:<br>ក) ប្រភេទឧបករណ៍<br>ខ) រោងចក្រផលិត<br>គ) ម៉ូដែល<br>ឃ) លេខស៊េរី<br>ង) ថ្ងៃ ខែ ឆ្នាំផលិត | បំពេញព័ត៌មានខាងក្រោម:<br>ក) ប្រភេទ:__________<br>ខ) រោងចក្រផលិត:__________<br>គ) ម៉ូដែល:__________<br>ឃ) លេខស៊េរី:__________<br>ង) ថ្ងៃ ខែ ឆ្នាំផលិត:__________ |
| | **២. បញ្ជាក់ពីស្ថានភាពឧបករណ៍មុនពេលផ្តល់ជូន (ដំណើរការ ឬមិនដំណើរការ)**<br>ភាគីផ្តល់ជំនួយត្រូវត្រួតពិនិត្យ និងបញ្ជាក់អំពីស្ថានភាពឧបករណ៍បរិក្ខារពេទ្យដែលត្រូវផ្តល់ជំនួយ ដើម្បីឱ្យដឹងថាមានស្ថានភាពដំណើរការល្អដែរឬទេមុនពេលប្រគល់ជូនមន្ទីរពេទ្យ ។ | ភាគីផ្តល់ជំនួយត្រូវធ្វើតេស្តដំណើរការឧបករណ៍បរិក្ខារពេទ្យដែលត្រូវផ្តល់ជំនួយដើម្បីឱ្យដឹងថាតើឧបករណ៍នោះមានដំណើរការល្អដែរឬទេ? | ស្ថានភាពដំណើរការ:<br><br>__________ |

| | | | |
|---|---|---|---|
| | **៣. ភ្ជាប់មកជាមួយនូវគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ និងគ្រឿងប្រើប្រាស់ប្រចាំថ្ងៃ**<br>ភាគីផ្ដល់ជំនួយត្រូវធ្វើការត្រួតពិនិត្យដើម្បីបញ្ជាក់ថាគ្រឿងប្រើប្រាស់ប្រចាំថ្ងៃ គ្រឿងបន្ទាប់បន្សំ និងគ្រឿងចាំបាច់ផ្សេងៗមានភ្ជាប់មកជាមួយនឹងឧបករណ៍នោះ ។ | ភាគីផ្ដល់ជំនួយត្រូវផ្ដល់ជូនផងដែរនូវគ្រឿងប្រើប្រាស់ប្រចាំថ្ងៃ គ្រឿងបន្ទាប់បន្សំ និងគ្រឿងចាំបាច់ផ្សេងៗតាមតម្រូវការរបស់ឧបករណ៍ដែលមានរៀបរាប់នៅក្នុងឯកសារណែនាំពីរបៀបប្រើប្រាស់ឧបករណ៍ ។ | លទ្ធផលនៃការត្រួតពិនិត្យ:<br>______________<br>______________<br>______________ |
| | **៤. ឯកសារបច្ចេកទេស**<br>ភាគីផ្ដល់ជំនួយត្រូវធ្វើការត្រួតពិនិត្យដើម្បីបញ្ជាក់ថារាល់ឯកសារបច្ចេកទេសទាំងអស់មានភ្ជាប់មកជាមួយឧបករណ៍បរិក្ខារពេទ្យនោះ ។ | ឯកសារបច្ចេកទេសទាំងនោះរួមមាន:<br>ក. ឯកសារណែនាំពីរបៀបប្រើប្រាស់<br>ខ. ឯកសារណែនាំពីរបៀបថែទាំ ជួសជុល<br>គ. បញ្ជីឈ្មោះគ្រឿងបន្លាស់<br>ឃ. សៀវភៅបង្កាំ<br>ភាគីផ្ដល់ជំនួយត្រូវផ្ដល់ជូននូវឯកសារណែនាំដូចខាងលើនេះ យ៉ាងហោចណាស់ត្រូវមានឯកសារណែនាំពីរបៀបប្រើប្រាស់ ព្រោះវាមានសារៈសំខាន់ណាស់សម្រាប់ដំណើរការ និងប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យឱ្យបានសមស្រប ។ | ឯកសារបច្ចេកទេសដែលទទួលបាន:<br>______________<br>______________<br>______________<br>______________<br>______________<br>______________<br>______________<br>______________ |
| | **៥. រយៈពេលប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យ**<br>ភាគីផ្ដល់ជំនួយត្រូវផ្ដល់ព័ត៌មានពីចំនួនឆ្នាំដែលបានប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យដោយស្ថាប័នរបស់ខ្លួន ។ | ជំហានដំបូង ភាគីផ្ដល់ជំនួយត្រូវត្រួតពិនិត្យមើលពីចំនួនឆ្នាំដែលបានប្រើឧបករណ៍បរិក្ខារពេទ្យនោះពីមុន ។ បន្ទាប់មកគាត់ត្រូវជម្រាបព័ត៌មាននេះដល់ភាគីទទួលជំនួយ ។ | ចម្លើយរបស់ភាគីផ្ដល់ជំនួយ:<br><br>ចំនួនឆ្នាំដែលបានប្រើប្រាស់:__________ |

| | | | |
|---|---|---|---|
| | **៦. ស្ថានភាពបរិស្ថានពេលប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យ**<br>ភាគីផ្តល់ជំនួយត្រូវផ្តល់ព័ត៌មានទាក់ទងនឹងស្ថានភាពជុំវិញកន្លែងប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យនោះនាពេលកន្លងមក ដូចជាបរិយាកាស ឬ ធ្លាប់បានប្រើប្រាស់ច្រើន។ | ភាគីផ្តល់ជំនួយត្រូវជម្រាបជូនភាគីទទួលជំនួយពីស្ថានភាពបរិស្ថានជុំវិញកន្លែងប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យនាពេលកន្លងមក។ | ស្ថានភាពបរិស្ថានជុំវិញកន្លែងប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យពីមុនៈ<br>__________<br>__________ |
| | **៧. ការបណ្តុះបណ្តាលអ្នកប្រើប្រាស់**<br>ប្រសិនបើមន្ទីរពេទ្យទទួលឧបករណ៍បរិក្ខារពេទ្យទំនើប ឬស្មុគស្មាញក្នុងការប្រើប្រាស់ ចាំបាច់ត្រូវមានការបណ្តុះបណ្តាលអ្នកប្រើប្រាស់។ | ប្រសិនបើចាំបាច់ ភាគីផ្តល់ជំនួយត្រូវធ្វើការបណ្តុះបណ្តាលពីរបៀបប្រើប្រាស់ឧបករណ៍ និងជម្រាបជូនភាគីទទួលជំនួយពីព័ត៌មានសំខាន់ៗទាក់ទងនឹងការប្រើប្រាស់ឧបករណ៍នោះ។ | ចម្លើយរបស់ភាគីផ្តល់ជំនួយៈ<br>__________<br>__________<br>__________ |
| **III.** | **ការព្រមព្រៀងគ្នាទៅវិញទៅមក (រវាងភាគីផ្តល់ជំនួយ និងភាគីទទួលជំនួយ)** | នៅពេលដែលភាគីផ្តល់ជំនួយផ្តល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយដល់ភាគីទទួលជំនួយ ភាគីទាំងពីរគួរធ្វើការព្រមព្រៀងគ្នាទៅវិញទៅមកនូវបញ្ហាមួយចំនួនដូចខាងក្រោមដើម្បីជៀសវាងការយល់ច្រឡំ និងឧបសគ្គផ្សេងៗ។ | សម្គាល់ |
| | **១. ការទទួលខុសត្រូវលើចំណាយដំបូងនៅពេលប្រគល់ឧបករណ៍បរិក្ខារពេទ្យ**<br>នៅពេលភាគីផ្តល់ជំនួយប្រគល់ឧបករណ៍ដល់ភាគីទទួលជំនួយ ភាគីទាំងពីរគួរបញ្ជាក់ឱ្យបានច្បាស់លាស់ថាតើភាគីណា (ភាគីទទួលឬភាគីផ្តល់ជំនួយ) ទទួលខុសត្រូវលើការចំណាយដំបូង។ | ត្រូវធ្វើការពិភាក្សាឱ្យបានច្បាស់លាស់រវាងភាគីផ្តល់ជំនួយ និងភាគីទទួលជំនួយថាតើនណាជាអ្នកទទួលខុសត្រូវចំពោះចំណាយខាងក្រោមៈ<br>ក. ថ្លៃដឹកជញ្ជូន (ទៅកាន់ទីកន្លែងផ្តល់ជំនួយ)<br>ខ. ថ្លៃដំឡើង | តើភាគីណាជាអ្នកទទួលខុសត្រូវលើការចំណាយដូចខាងក្រោមនេះៈ<br>ក. ថ្លៃដឹកជញ្ជូន<br>__________<br>ខ.ថ្លៃដំឡើង |

| | | | |
|---|---|---|---|
| | | គ. ថ្លៃថែទាំ<br>ឃ. ចំណាយផ្សេងៗ ( ប្រសិនបើមាន) | ________________<br>គ.ថ្លៃថែទាំ<br>________________<br>ឃ. ចំណាយផ្សេងៗ ( ប្រសិនបើមាន)<br>________________ |
| | **២.អនុស្សរណៈនៃការយោគយល់គ្នាក្នុងការប្រគល់ឧបករណ៍បរិក្ខារពេទ្យ**<br>ធ្វើអនុស្សរណៈនៃការយោគយល់គ្នាក្នុងការប្រគល់ឧបករណ៍បរិក្ខារពេទ្យរវាងភាគីផ្តល់ជំនួយ និងភាគីទទួលជំនួយ ដោយធ្វើការបញ្ជាក់អំពីការទទួលខុសត្រូវរបស់ភាគីនីមួយៗឱ្យបានច្បាស់លាស់ ។ | រៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាងអ្នកផ្តល់ជំនួយ និងអ្នកទទួលជំនួយដែលមានខ្លឹមសារដូចខាងក្រោមៈ<br>ក. និយមន័យ និងព្រំដែននៃការប្រគល់ឧបករណ៍<br>ខ. ការផ្ទេរកម្មសិទ្ធិ<br>គ. ការទទួលខុសត្រូវលើការគ្រប់គ្រងថែទាំ<br>ឃ. សិទ្ធិនៃការសុំជម្រះបញ្ជី<br>ង. ព័ត៌មានសម្រាប់ទំនាក់ទំនង | តើមានរៀបចំអនុស្សរណៈនៃការយោគយល់គ្នាដែរឬទេ?<br>បាទ /ចាស ឬ ទេ |
| | **៣. ការផ្តល់សិទ្ធិលើស្តង់ដាផលិតផលដើម**<br>ភាគីផ្តល់ជំនួយត្រូវបញ្ជាក់ថាឧបករណ៍បរិក្ខារពេទ្យដែលត្រូវផ្តល់ជូនភាគីទទួលជំនួយនោះមានបិតស្លាកអនុញ្ញាតការផលិតតាមបទដ្ឋានសម្រាប់ធានាពីគុណភាពឧបករណ៍ (ដូចជាបទដ្ឋានឧស្សាហកម្មនៃប្រទេសជប៉ុន និង សញ្ញាសម្គាល់ផលិតផលរបស់សហគមន៍អឺរ៉ុបជាដើម) ។ | ស្លាកអនុញ្ញាតការផលិតនេះគឺជាចំណុចបន្ថែមនៃល័ក្ខខ័ណ្ឌដំបូង ។ ម្ចាស់ជំនួយនិងអ្នកទទួលគួរតែពិភាក្សាគ្នាថាតើស្លាកអនុញ្ញាតនេះមានសារៈសំខាន់ដែរឬទេ ។ | តើឧបករណ៍មានបិតស្លាកអនុញ្ញាតការផលិតដែរ ឬទេៈ<br>មាន /អត់<br>________________ |

## ឧបសម្ព័ន្ធ-៣៖ បញ្ជីនៃគ្រឿងបន្ទាប់បន្សំ គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ និងគ្រឿងបន្លាស់សម្រាប់ឧបករណ៍បរិក្ខារពេទ្យដែលចាំបាច់

| 1. X-ray Diagnostic equipment |
|---|
| Accessories:<br><br>① X-ray film cassette<br>② X-ray screen<br> |
| Consumables:<br><br>① X-ray film<br> |

| 2. X-ray Film Processor |
| --- |
| Accessories: |
| Consumables:<br><br>① Developer solution<br>② Fixer solution<br><br> |

| 3. Ultrasound scanner |
| --- |
| Accessories:<br><br>① Convex type probe<br>② Virginal type probe<br><br>  |
| Consumables:<br><br>① Echo Gel<br><br><br> |

4. Electrocardiograph (E.C.G.)

Accessories:

① Patient cable
② Arm stand
③ SPO2 probe





Consumables:

① Patient electrode
② Electrode gel





5. Patient Monitor

Accessories:

① Patient cable
② Arm stand
③ SPO2 probe
④ Cuff of sphygmomanometer









Consumables:

① Patient electrode





6. Defibrillator

Accessories:

① Patient paddle
② Paddle electrode
③ ECG electrode
④ Joint cable









Consumables:

① Rechargeable battery
② Paddle gel





| 7. Pulse Oximeter |
|---|
| Accessories:<br><br>① SPO2 finger probe<br>② Joint cable<br><br>  |
| Consumables:<br><br>① Disposable SPO2 Probe (for child use)<br><br> |

8. Respirator

Accessories:

① Oxygen monitor
② Test lung bag
③ Water trap
④ Spiro meter





Consumables:

① Patient circuit tube
② Bacteria filter
③ Respiration filter
④ Patient mask
⑤ Humidifier








| 9. Oxygen concentrator |
| --- |
| Accessories:<br><br>① Oxygen humidifier<br><br> |
| Consumables:<br><br>① Oxygen filter (consuming spare parts)<br><br><br> |

| 10. Nebulizer |
| --- |
| Accessories:<br><br>① Nebulizing unit<br>② Nebulizing tube<br><br>  |
| Consumables:<br><br>① Disposal mask<br>② Medicine cup<br>③ Bacteria filter<br><br>  |

## 11. Infusion pump

Accessories:

1) Rechargeable battery
2) Irrigation stand






Consumables:

1) Transfusion set (exclusive design by manufacture)





12. Anesthesia apparatus

Accessories:

1) Test lung bag
2) Evaporator
3) Oxygen monitor





Consumables:

1) CO2 absorber
2) Patient circuit
3) Mask





## 13. Electro Surgical Unit

Accessories:

1) Electrode cable
2) Bipolar electrode
3) Single type electrode







Consumables:

1) Electrode chip
2) Patient plate with cable
3) Patient cable (Disposal type)









## 14. Suction unit

Accessories:

1) Suction bottle set (with rubber cap and tube connection)
2) Flow tube
3) Insert tube





Consumables:

1) Silicon tube
2) Catheter stopper
3) Suction catheter







## 15. Operation table

Accessories:

1) Arm mat
2) Curtain hook
3) Leg holder
4) X-ray cassette holder
5) Knee holder
6) Head holder













## 16. Operating light

Accessories:



Consumables:

1) Spare halogen lamp





## 17. Operation microscope

Accessories:

1) Video attachment
2) Foot switch



OMS-90

Consumables:

1) Halogen lamp



18. Steam Sterilizer

Accessories:

1) Sterilizing box



Consumables:

1) Door gasket
2) Sterilizing indicator





19. Infant Incubator

Accessories:

1) Irrigator pole
2) Temperature probe
3) Oxygen flow meter





Consumables:

1) Vinyl food
2) Micro filter
3) Thermometer
4) Humidifier chamber
5) Temperature probe cover







20. Bilirubin meter

Accessories:

1) Incubation unit



Consumables:

1) Tungsten lamp
2) Filament lamp
3) Capillary tube







21. Phototherapy unit

Accessories:

1) Resuscitation unit
2) Oxygen mixing chamber
3) Suction bottle
4) Humidifier









Consumables:

1) Fluorescent lamp for phototherapy



| 22. Doppler Fetus Detector |
| --- |
| Accessories:<br>1) Doppler transducer<br>  |
| Consumables:<br>1) Gel for Doppler monitoring<br> |

23. Cardiotocograph

Accessories:

1) Doppler transducer (3 p individual)
2) Doppler transducer (Complex type)
3) Equipment cart







Consumables:

1) Recording paper
2) Transducer gel
3) Transducer belt
4) Pen cleaner for recording









## 24. Centrifuge

Accessories:

1) Swing rotor
2) Angle rotor
3) Tube bracket







Consumables:

1) Carbon brush



25. Microscope

Accessories:

1) Objective lens
2) Eye piece lens
3) Condenser lens







Consumables:

1) Imaging oil



| 26. Spectrophotometer |
| --- |

Accessories:

1) Thermal printer
2) Glass cell
3) Incubator cubet






Consumables:

1) Tungsten lamp
2) Recording paper
3) Printer ribbon



27. Water Distiller

Accessories:

1) Pipe heater (Spare parts)





Consumables:

1) Carbon filter cartridge
2) Ion exchange resin





| 28. Clean bench |
|---|
| Accessories: |
| Consumables:<br>1) HEPA filter<br>2) Fluorescent lamp)<br><br><br> |

| 29. pH meter |
| --- |

Accessories:

1) Electrode stand
2) Electrode arm
3) Chip electrode
4) pH electrode









Consumables:

1) pH standard solution
2) Cleaning solution





| 30. Water bath |
|---|
| Accessories:<br>1) Heater unit<br>2) Pipe heater (Spare parts)<br>  |
| Consumables: |

31. Laboratory incubator

Accessories:

1) Door gasket
2) Shelf



Consumables:

## 32. Dental chair unit

Accessories:

1) Air turbine hand piece
2) Micro motor hand piece





Consumables:

1) Hand piece chip (Metal bar)
2) Hand piece chip (Diamond bar)






| 33. Syringe pump |
|---|
| Accessories:<br>1) Syringe pump stand<br><br> |
| Consumables:<br>1) Rechargeable battery<br>2) Disposal syringe<br>  |

| 34. UV Sterilizing Scrub unit for OT |
|---|
| Accessories: |
| Consumables:<br>1) Fluorescent lamp<br>2) Ultraviolet lamp for sterilizing<br>3) Carbon filter<br>4) Membrane filter<br><br><br> |

35. Vacuum Extractor

Accessories:

1) Extraction cup
2) Amniotic vacuum tube
3) Suction bottle and rubber cover







Consumables:

1) Bacteria filter



## ឧបសម្ព័ន្ធ៤៖ បញ្ជីឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍បរិក្ខារពេទ្យក្នុងស្រុក

| No. | Company's name | Person's name; position | Telephone | Fax | Address | Website & E-mail | Dealing Manufacture |
|---|---|---|---|---|---|---|---|
| 1 | MediGroup Asia Ltd | Mrs. Sao Makarachan (Sales Supervisor) | 023 727 109/ 023 727 108 | 023 727 109 | #91; Oknha Chrun Youhak (St. 294) | eric.meerman@mg.com.kh | Laboratory:Human (Germany) Medical Equipment: GE (American) |
| 2 | Medicom Co., LTD. | Mr. Jean Yves CATRY (Managing Director) | 023 220 691/ 023 217 573 | 023 215 691 | #22, St 184, Phnom Penh, Cambodia | info@medicomcoltd.com<br>www.medicomcoltd.com | FUKUDA DENSHI, RICHARO WOLF, VWR, ERMA, AIR LIQUIDE. |
| 3 | Dynamic Pharma Co., LTD | Mr. Pak Soeun (Service Supervisor) | 023 726 018 | 023 726 016 | #432, St Preah Monivong | pharma@dynamic.com.kh | Abbott, Becton and Dickinson, Ebewe Pharma, Fujirebio Diagnostics,Inc. , Golden Cup Pharmaceutical Co.,Ltd , Greater Pharma, Medtronic, Nature Care, Nipro Corp.,Ltd , Olympus, Omron Healthcare Co.,Ltd , Paramount, PT. Dexa Medica, Respironic ,Sanyo, Schiller, T.C Union Global Public, Takaso Rubber Products Sdn. Bhd , Terumo, The Government Pharmaceutical Organization, Titleray Dental Implants-Straumann, Toshiba |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 4 | KUANG HSIEN Medical Instrument Co., LTD | Mr. Narin (Sale Manager) | 023 882 829/<br>023 885 799/<br>017 757 595/<br>016 861 494/<br>012 958 709/<br>012 620 704 | 023 885 798 | #131Z, St 265, Tuk Laak II, Toul Kork, Phnom Penh | rapidservice@camnet.com.kh | Sysmex, Elitech group, Heinz, Hirschmann, GBO, Analyticon, Pointe scientific, BioHit, Biotix, Chison, Diamond |
| 5 | MIG Group Co Ltd | Mr. Ly Bunleng (General Manager) | 023 224 673/<br>023 224 674/<br>012 710 509/<br>012 765 506/<br>016 445 573/<br>012 337 112 /<br>011 701 244 /<br>017 502 759 | 023 224 674/<br>023 224 673 | #113A, Street 103 | mig_group@online.com.kh | Microlab 300, Sturdy, Hettich, Nihon Kollden, Japan, USA, Taiwan, Korea, China, Thailand, Italy, Germany |
| 6 | MEES | Mr. Sam Tetra (General Manager) | 023 883 118/<br>011 606 019/<br>012 858 734 | 023 883 118 | #295C, Oknha Tep Phan (St. 182) 12157 Phnom Penh Phnom Penh | mees@everyday.com.kh | Hitachi, Carl Zeiss, Aloka, Inami, Stryker, Fujinon, Ameri-comp, ERBE, Mindray, Acoma, Hadeco, Daiwha, Takeuchi, Sturdy, Hersill, Technologie Medical, Ellipse, AceLaser Lightmed, Leisegang |
| 7 | MET GROUP CO., LTD | Mr.Keo Vibol (General Manager) | 023 220 827/<br>012 836 608/<br>016 826 792/<br>097 8282351/<br>011 249 144/<br>015 249 144 | 023 215 953 | #297, Sihanouk (St. 274), Phnom Penh | met@online.com.kh | SHIMADZU, MEDISON, NIHON KOHDEN, HOLOGIC, MEK, PATIENT CARE EQUIPMENT, BOKWANG, OPERATING EQUIPMENT |
| 8 | Ly Owtry | Mr. Ly Owtry (General Manager) | 023 220 735/<br>016 816 056/<br>012 440 641 | | # 284AEo, Canadia (St. 284) 12312 Phnom Penh | | Honda, INAMJ, Shimazu |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 9 | H.S.R Co., Ltd. | Ms. Chhun Nary<br>(Sale Manager) | 081 822 822 | 023 995 470 | # 34, Street 376, Boeung Keng Kang III, Chamkar Morn | sales@hsrco.com/<br>hsr822@gmail.com | Meditech |
| 10 | Safety - Tech Co Ltd | Mr. Kim Heang<br>(General Manager) | 012 980 535/<br>016 980 535 | | # 300Eo, Street 150 , Sangkat kek lork II, Tul kork Phnom Penh | | AIRLIFE, Airial, ACCURATE ONE TOUCH ULTRA |
| 11 | Europe Continents | Mr. Khy Srun<br>(Healthcare Senior Sales) | 012 645 502/<br>023 986 228 | | #22, St 184, Phnom Penh, Cambodia | healthcarecb@europ-continents.com | Apelem, Philip, Sturdy, Aloka, ABZ, MEDICA, Korea, China, Storz, Fujinon |
| 12 | Khmer Healthcare Co Ltd | Mr. Sochea Meas<br>(General Manager) | 023 222 238/<br>011 234 999 | | # 343AB, Tumnup Thmey (St. 371)<br>12351 Phnom Penh | sochea.meas@khc.com.kh/<br>salesinfo@khmerhealthcare.com | Heine-Germany, Hamilton Medical-Switzerland, Raphael XTC, Hamilton C-2 and Galileo Goal, Boule Swelab, Alfa-Sweden, CYAN Express-Belgium, Royal-Medical-Korea, Infopia-Korea, Rexmed-Taiwan, Daiwah-Korea, Mingchu Corp-Korea, NewTech-USA |
| 13 | Kim Tech Co Ltd | Mr. Var Seila<br>(Sale & marketing) | 023 218 121/<br>012 511 561/<br>016 826792/<br>092 123 201 | | # 362, Sihanouk (St. 274)<br>12312 Phnom Penh | kimtech@online.com | Medison, Kongsak (KELEX), Hyundai, SAMIL, Bionet |

# ឧបសម្ព័ន្ធ ៥: គម្រូអនុស្សរណៈនៃការយោគយល់គ្នាក្នុងការប្រគល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ

អង្គភាពផ្តល់ជំនួយ (ភាគីផ្តល់ជំនួយ) និងមន្ទីរពេទ្យ (ភាគីទទួលជំនួយ) យល់ព្រមគ្នាតាមមាត្រាមួយចំនួនដូចខាងក្រោម ទាក់ទងនឹងការប្រគល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយៈ

**មាត្រា ១: និយមន័យ និង ព្រំដែននៃការប្រគល់ឧបករណ៍**

មាត្រានេះមានបំណងកំណត់អំពីព្រំដែននៃការប្រគល់ឧបករណ៍។ ភាគីផ្តល់ជំនួយទទួលខុសត្រូវក្នុងការប្រគល់ឧបករណ៍បរិក្ខារពេទ្យដល់មន្ទីរពេទ្យរហូតដល់ឧបករណ៍នោះត្រូវបានដំឡើងរួចរាល់ហើយអាចប្រើបាន។

ការទទួលខុសត្រូវរបស់ភាគីផ្តល់ជំនួយគឺៈ

១. ការដឹកជញ្ជូនៈ ការចំណាយក្នុងការដឹកជញ្ជូនឧបករណ៍ពីទីកន្លែងប្រើប្រាស់ ឬឃ្លាំងរបស់ភាគីផ្តល់ជំនួយទៅដល់ទីកន្លែងប្រើប្រាស់របស់ភាគីទទួលជំនួយ រួមទាំងពន្ធ និងចំណាយដែលចាំបាច់មួយចំនួន។

២. ការដំឡើងៈ ការដំឡើងឧបករណ៍នៅទីកន្លែងប្រើប្រាស់របស់ភាគីទទួលជំនួយ រួមទាំងការផ្គុំឧបករណ៍ឡើងវិញ និងចំណាយចាំបាច់មួយចំនួននៅទីនោះ។

៣. ការធ្វើតេស្តដំណើរការៈ ភាគីផ្តល់ជំនួយរៀបចំបញ្ជូនអ្នកឯកទេសមួយចំនួន (បុគ្គលិករបស់អង្គភាពគាត់ ឬវិស្វកររបស់រោងចក្រផលិតជាដើម) ដែលមានលទ្ធភាពអាចធ្វើតេស្តដំណើរការឧបករណ៍នោះបាន ដើម្បីបញ្ជាក់ពីមុខងារទាំងអស់របស់វា។

៤. ការបណ្តុះបណ្តាលអ្នកប្រើប្រាស់ៈ ភាគីផ្តល់ជំនួយត្រូវរៀបចំបញ្ជូនអ្នកណែនាំទៅបង្រៀន និងបណ្តុះបណ្តាលអ្នកប្រើប្រាស់ឧបករណ៍ខាងភាគីទទួលជំនួយ។

៥. ការប្រគល់ៈ បន្ទាប់ពីបានបំពេញនូវរាល់ចំណុចនីមួយៗដែលបានរៀបរាប់ខាងលើ ភាគីផ្តល់ជំនួយនឹងផ្ញើរបាយការណ៍នៃការប្រគល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយទៅភាគីទទួលជំនួយ ដោយមានហត្ថលេខាយល់ព្រមរវាងភាគីទាំងពីរ។

**មាត្រា ២: ការផ្ទេរកម្មសិទ្ធិ**

បន្ទាប់ពីការប្រគល់ឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយពីម្ចាស់ជំនួយដល់អ្នកទទួលជំនួយ ម្ចាស់កម្មសិទ្ធិនឹងត្រូវបានផ្ទេរពីម្ចាស់ជំនួយទៅអ្នកទទួល។ ទោះបីជាយ៉ាងនេះក៏ដោយ មុនពេលប្រគល់ឧបករណ៍ ភាគីផ្តល់ជំនួយគួរតែទទួលខុសត្រូវចំពោះការដឹកជញ្ជូនទៅកាន់ទីកន្លែងរបស់អ្នកទទួលឧបករណ៍ ការផ្គុំ ការដំឡើង ការធ្វើតេស្តដំណើរការ និងការបណ្តុះបណ្តាលអ្នកប្រើប្រាស់។

**មាត្រា ៣: ការទទួលខុសត្រូវលើការគ្រប់គ្រងថែទាំ**

យោងតាមការផ្ទេរកម្មសិទ្ធិពីអ្នកផ្តល់ជំនួយទៅកាន់អ្នកទទួលជំនួយខាងលើ អ្នកទទួលជំនួយគួរតែទទួលខុសត្រូវលើការងារគ្រប់គ្រងថែទាំឧបករណ៍នោះដើម្បីឱ្យការដំណើរការ ការប្រើប្រាស់បានសមស្រប និងមានប្រសិទ្ធភាព។ ហេតុដូចនេះ អ្នកទទួលជំនួយមានភារកិច្ចរៀបចំថវិកាសម្រាប់ចំណាយលើជំនួយបច្ចេកទេស និងការគ្រប់គ្រងថែទាំឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយនោះ។

**មាត្រា ៤: សិទ្ធិនៃការសុំជម្រះបញ្ជី**

យោងតាមភាពនៃកម្មសិទ្ធិ អ្នកទទួលជំនួយមានការទទួលខុសត្រូវ និងមានអំណាចក្នុងការជម្រះបញ្ជីឧបករណ៍បរិក្ខារពេទ្យដែលទទួលបានពីម្ចាស់ផ្តល់ជំនួយនោះ។

**មាត្រា ៥: ព័ត៌មានទំនាក់ទំនង**

ក្នុងការរក្សាឱ្យមានទំនាក់ទំនងល្អរវាងម្ចាស់ជំនួយនិងអ្នកទទួលជំនួយ ភាគីទាំងពីរគួរតែបន្តទំនាក់ទំនងជាមួយគ្នាតាមមធ្យោបាយ និងព័ត៌មានដូចខាងក្រោម:

ភាគីផ្តល់ជំនួយ:

| | |
|---|---|
| ឈ្មោះអង្គភាព | |
| អ្នកទទួលបន្ទុក | |
| អាស័យដ្ឋាន | |
| លេខទូរស័ព្ទ | |
| លេខទូរសារ | |
| សារអេឡិចត្រូនិច (អ៊ីម៉ែល) | |
| សម្គាល់ | |

ភាគីទទួលជំនួយ:

| | |
|---|---|
| ឈ្មោះអង្គភាព | |
| អ្នកទទួលបន្ទុក | |
| អាស័យដ្ឋាន | |
| លេខទូរស័ព្ទ | |
| លេខទូរសារ | |
| សារអេឡិចត្រូនិច (អ៊ីម៉ែល) | |

ដើម្បីជាសក្ខីភាព អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវបានយល់ព្រម និងចុះហត្ថលេខាដោយភាគីទាំងពីរ ហើយភាគីនីមួយៗរក្សារទុកឯកសារដែលបានចម្លងត្រឹមត្រូវតាមច្បាប់ដើមមួយច្បាប់ ។

ភ្នំពេញថ្ងៃទី ~~ ខែ ~~ឆ្នាំ ២០១០

| | |
|---|---|
| ម្ចាស់ជំនួយ | អ្នកទទួលជំនួយ |
| | |
| លោក ~~~~~~~ | លោក ~~~~~~~~~~ |
| ឈ្មោះអង្គភាព~~~~~~~~ | មន្ទីរពេទ្យ ~~~~~~~~~~~ |
| នាយកគ្រប់គ្រង | ប្រធានមន្ទីរពេទ្យ |

## ឧបសម្ព័ន្ធ-៦: ព័ត៌មាននៃឧបករណ៍បរិក្ខារពេទ្យ (សម្រាប់ទទួលយកឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ)

លេខរៀង:________

ឈ្មោះមន្ទីរពេទ្យ : ______________________________________________

| | | | |
|---|---|---|---|
| លេខ ID | | ថ្ងៃ ខែ ឆ្នាំ តំឡើង | / / |
| ឈ្មោះផ្នែក | | | |
| កាលបរិច្ឆេទការត្រួតពិនិត្យ | ត្រួតពិនិត្យដោយ ( ឈ្មោះ និងហត្ថលេខារបស់ MET ) | | |
| កាលបរិច្ឆេទការយល់ព្រម | យល់ព្រមដោយ ( ឈ្មោះ និងហត្ថលេខារបស់ MEDM ) | | |

| | | | |
|---|---|---|---|
| ឈ្មោះឧបករណ៍ពេទ្យ | | | |
| ឈ្មោះឧបករណ៍ពេទ្យ ( ជាភាសាខ្មែរ ) | | | |
| រោងចក្រផលិត | | ម៉ូដែល | |
| លេខសេរី | | តម្លៃ (US$) | |
| ឆ្នាំផលិត | | កាលបរិច្ឆេទផុតធានារ៉ាប់រង | |

| | | |
|---|---|---|
| ការផ្គត់ផ្គង់ថាមពល | តង់ស្យុង | 100 / 110 / 120 / 220 / 230 / 240 V AC |
| | ហ្វ្រេកង់ស៍ | 50 / 60 Hz |
| | ហ្វា | 1 ហ្វា / 3 ហ្វា |
| | ថាមពលប្រើប្រាស់ | W / A |

| | | |
|---|---|---|
| ឯកសារណែនាំពីរបៀបប្រើប្រាស់ឧបករណ៍ | របៀបប្រើប្រាស់ | ខ្មែរ / អង់គ្លេស / ផ្សេងៗ |
| | របៀបថែទាំជួសជុល | ខ្មែរ / អង់គ្លេស / ផ្សេងៗ |
| | ឈ្មោះអ្នករក្សាទុកឯកសារណែនាំនេះ | |

| គ្រឿងបន្ទាប់បន្សំ (Accessories) | ម៉ូដែល | ព័តិមានលម្អិត | តម្លៃ (US$) | ចំនួន |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

| គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ (Consumables) | ម៉ូដែល | ព័ត៌មានលំអិត | តម្លៃ (US$) | ចំនួន |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

| | |
|---|---|
| ការធ្វើតេស្តដំណើរការមុខងារ | ល្អ / មធ្យម / អន់ / មិនដឹង |
| | យោបល់ផ្សេងៗ (លើកលែងតែក្នុងករណី "ល្អ"): |
| អ្នកត្រួតពិនិត្យ | |

| | | | |
|---|---|---|---|
| ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុក | | | |
| ឈ្មោះអ្នកទទួលបន្ទុក | | | |
| អាស័យដ្ឋានក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុក | | | |
| | ទូរស័ព្ទ | | ទូរសារ |

| | |
|---|---|
| អ្នកផ្តល់ជំនួយ | |

| កំណត់ត្រាការបណ្តុះបណ្តាលអ្នកប្រើប្រាស់ | | | | |
|---|---|---|---|---|
| កាលបរិច្ឆេទ | សមាសភាពចូលរួម | ខ្លឹមសារនៃការបណ្តុះបណ្តាល | បណ្តុះបណ្តាលដោយ | សម្គាល់ |
| | | | | |
| | | | | |
| | | | | |
| | | | | |

| កំណត់ត្រាការបណ្តុះបណ្តាលការថែទាំ | | | | |
|---|---|---|---|---|
| កាលបរិច្ឆេទ | សមាសភាពចូលរួម | ខ្លឹមសារនៃការបណ្តុះបណ្តាល | បណ្តុះបណ្តាលដោយ | សម្គាល់ |
| | | | | |
| | | | | |
| | | | | |

| | |
|---|---|
| កាលបរិច្ឆេទសុំជម្រះបញ្ជី | |
| សំគាល់: | |